COSECAM

# មជ្ឈមណ្ឌលស្តារលទ្ធភាពកុមារ



## បំណង ផ្ទុយទៅនឹង ភាពពិត

ចន វីហ្គេន

គំរោងផ្តល់មូលនិធិដោយ

Global Ministries Netherlands (KIA)
Welfare Stamps Foundation Netherlands (SKN)
Canadian International Development Agency (CIDA)

របាយការណ៍លេខ ០១១

# មជ្ឈមណ្ឌលស្តារលទ្ធភាពកុមារ
# បំណង ផ្ទុយទៅនឹង ភាពពិត

ដោយ John Vijghen

ទីប្រឹក្សា COSECAM [១]

## សេចក្តីផ្តើម

កុមារ និងស្ត្រីក្មេងៗរាប់រយនាក់ក្នុងប្រទេសកម្ពុជាត្រូវការទីជម្រកជាបណ្តោះអាសន្នដោយសារពួកគេត្រូវគេជួញដូរទទួលរងនូវការកេងប្រវ័ញ្ច ឬត្រូវគេរំលោភសិទ្ធិតាមវិធីផ្សេងៗ។ ទីជម្រកមួយចំនួនដែលមានឈ្មោះថា មជ្ឈមណ្ឌលស្តារលទ្ធភាពកុមារ (Child Recovery Centres) ផ្តល់ការការពារ និងគាំទ្រកុមារ និងស្ត្រីវ័យក្មេងទាំងនោះរហូតដល់ពួកគេអាចវិលត្រឡប់ទៅនៅជាមួយគ្រួសាររបស់គេវិញ ឬក៏អាចរកស៊ីចិញ្ចឹមជីវិតដោយខ្លួនឯងបាន។ ក្នុងកំឡុងឆ្នាំ ២០០២ និង២០០៣[២] សម្ព័ន្ធអង្គការក្នុងស្រុក១ (COSECAM ) ធ្វើការលើបញ្ហាជួញដូរ ការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារ បានរៀបចំការសិក្សាលើទីជម្រក ឬមណ្ឌលថែទាំកុមារ និងស្ត្រីវ័យក្មេងដែលត្រូវគេរំលោភបំពាន។ ផ្អែកលើការប៉ាន់ប្រមាន និងលើធនធានដទៃៗទៀត របាយការណ៍នេះ ចង់រៀបរាប់អំពីស្ថានភាពនៅតាមទីជម្រក និងពីរបៀបដែលមជ្ឈមណ្ឌលនោះដំណើការពីសមត្ថភាពរបស់មណ្ឌលទាំងនោះ ពីចំនុចខ្លាំងនិងជាចំនុចខ្សោយ និងពីឧបសគ្គដែលគេជួបប្រទះ។ យើងនឹងធ្វើការពិភាក្សានូវគោលនយោបាយ ដែលជាមូលដ្ឋាននៃដំណើការការ និងគោលការណ៍ណែនាំពីការដំណើរការមណ្ឌលរបស់គេ។

## អតិថិជនដែលត្រូវគេរំលោភបំពាន មិនត្រូវបានយកចិត្តទុកដាក់ ឬគ្មានជំនាញ

ការចាត់ចំណាត់ថ្នាក់អតិថិជន គឺមានប្រយោជន៍ប្រសិនបើត្រូវគេប្រើដើម្បីធ្វើអោយមានការថែទាំ និងផ្តល់សេវាដល់ពួកគេកាន់តែប្រសើរ។ អតិថិជនដែលមានប្រវត្តិខុសគ្នាត្រូវការថែទាំ និងបំរើសេវាខុសៗគ្នាដែរ។ ដូច្នេះតំរូវការនេះ តំរូវអោយធ្វើទៅតាមការបែងចែកចំណាត់ថ្នាក់ អតិថិជននៅតាមមជ្ឈមណ្ឌលជាមូលដ្ឋាន។ កុមារដែលត្រូវគេជួញដូរផ្លូវភេទក្នុងបរិបទពាណិជ្ជណិជ្ជកម្មដែលត្រូវគេជួញដូរ និងបង្ខំឱ្យធ្វើជាពេស្យាចារ ពួកគេត្រូវការសេវាចិត្តសាស្ត្រសង្គមជាពិសេស។ កុមារដែលត្រូវគេរំលោភតែមិនត្រូវគេជួញដូរក៏ត្រូវការសេវាចិត្តសាស្ត្រស្រដៀងនេះដែរដើម្បីជួយពួកគេពីការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរលើផ្លូវចិត្ត។ ស្រដៀងទៅនឹងករណីទាំងនេះដែរ គឺការ

---

[១] សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅប្រទេសកម្ពុជា (COSECAM)

[២] ការស្ទាបស្ទង់សមត្ថភាពរបស់អង្គការមូលដ្ឋាន (CLO) ក្នុងឆ្នាំ២០០២-២០០៣ ដែលឧបត្ថម្ភដោយ Dutch Embassy Bangkok

រំលោភបំពានផ្លូវភេទដែលទទួលនូវការសើចចំអក និងបាត់បង់នូវការគោរពពីសង្គម។ ហេតុដូច្នេះ សេវាផ្សេងៗ និងការពិគ្រោះ យោបល់ពិសេសសំរាប់ការរំលោភបំពានបែបនេះ គឺជាមូលដ្ឋាននៃការចំណាត់ថ្នាក់។

កុមារ និងស្ត្រីវ័យក្មេងៗដែលត្រូវគេកេងប្រវ័ញ្ច និងរំលោភបំពាន ឧទាហរណ៍ អ្នកបំរើតាមផ្ទះ អ្នកសុំទាន ឬធ្វើការនៅក្នុងហាងលក់ដូរ ក៏ត្រូវការសេវាផ្នែកសង្គមផងដែរ ប៉ុន្តែប្រភេទសេវាទាំងនោះខុសៗគ្នា។ ការកំណត់ជាទូទៅលើករណីរបស់គេ គឺការកេងប្រវ័ញ្ចលើកំលាំងពលកម្ម។ ក្រុមមួយទៀត ត្រូវបង្កើតឡើងដោយកុមារ និងស្ត្រីដែលជាជនរងគ្រោះដោយការប្រើអំពើហឹង្សាក្នុងគ្រួសារ។ អតិថិជនទាំងនេះក៏ត្រូវការផងដែរនូវសេវាផ្នែកសង្គម និងការពិគ្រោះយោបល់ ហើយក៏ត្រូវការសេវាប្រភេទខុសគ្នាផងដែរ។

អ្វីទាំងអស់ដែលគេចែករំលែក គឺជាតំរូវការសំរាប់ពិគ្រោះយោបល់ដើម្បីយកឈ្នះ លើការប៉ះទង្គិចផ្លូវចិត្តរបស់គេបាន។ យើងសំណូមពរអោយចាត់ថ្នាក់អតិថិជនក្នុងចំណោមអតិថិជន ជាប្រភេទទីមួយ គឺអក្ខដែលត្រូវការពិគ្រោះយោបល់ផ្លូវចិត្ត និងអតិថិជនថ្នាក់ទី ២ គឺអ្នកដែលត្រូវគេរំលោភបំពានផ្លូវភេទ ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ឬត្រូវគេរំលោភតាមរយៈការងារ។ ការកំណត់អតិថិជនសមស្របសំរាប់អតិថិជនទាំងនេះគឺ <u>កុមារដែលត្រូវរំលោភបំពាន</u> ត្រូវការការពិគ្រោះយោបល់ផ្នែកចិត្តសាស្រ្ត។

អតិថិជនមួយប្រភទទៀត គឺកុមារដែលមានប្រវត្តិមិនត្រូវបានគេរំលោភបំពាន ប៉ុន្តែមិនត្រូវបានគេយកចិត្តទុកដាក់។ ទាំងនេះរួមមានកុមារនៅតាមផ្លូវ ឬកុមារអនាថា កុមារដែលគ្មានផ្ទះសម្បែង ដោយសារឪពុកម្តាយរបស់គេស្លាប់ដោយសារជម្ងឺអេដស៏ កុមារដែលផ្ទុក មេរោគហ៊ីវ/អេដស៏ ឬកុមារពិការ។ កុមារជាច្រើនក្នុងចំណោមកុមារទាំងនេះ មានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរលើផ្លូវចិត្ត ដែលពួកគេត្រូវការការពិគ្រោះយោបល់ព្យាបាលទៅតាមលក្ខណៈខុសគ្នាច្រើនជាងកុមារដែលត្រូវគេរំលោភបំពាន។ ក្នុងចំណោមក្រុមនេះ គឺមានកុមារដែលត្រូវការការថែទាំផ្នែកឱសថ និងផ្លូវកាយជាពិសេស។ យើងសូមហៅក្រុមនេះថាជា<u>កុមារ ដែលមិនត្រូវគេយកចិត្តទុកដាក់</u>ដែលត្រូវការការថែទាំ។

កុមារប្រភេទទីបី ជាញឹកញាប់ត្រូវប្រទះឃើញនៅក្នុងមជ្ឈមណ្ឌលស្តាលទ្ធភាពកុមារ គឺកុមារដែលងាយរងគ្រោះ"។ ក្រុមមួយទៀតគឺ ក្មេងស្រីជំទង់ៗ ដែលធ្វើការក្នុងអាជីពមួយដែលងាយរងគ្រោះនឹងការ រំលោភបំពានផ្លូវភេទ។ ស្រីលក់ស្រាបៀរ និងស្រីរបាំក៏ល្បីល្បាញណាស់ដែរ ប៉ុន្តែស្រីដែលធ្វើការក្នុងបារ ខារ៉ាអូខេ ហាងម៉ាសា ភោជនីយដ្ឋាន និងសណ្ឋាគារកមិនធម្មតាដែរ។ ប៉ុន្តែមិនមានស្ត្រីប្រភេទនេះច្រើនទេ ដែលបានរកឃើញនៅក្នុងមជ្ឈមណ្ឌលកុមារទាំងនោះ។ ប្រភេទទីពីរនៃកុមារងាយរងគ្រោះ" គឺក្មេងស្រីដែលមានអាយុពី ១៥ឆ្នាំ ទៅ ១៨ឆ្នាំ ដែលមានការអប់រំទាប ហើយមកពីគ្រួសារក្រីក្រដែលងាយរងគ្រោះដោយការជួញដូរ និងកេងប្រវ័ញ្ច ព្រោះពួកគេ (ចង់) ចេញពីផ្ទះដើម្បីស្វែងរកការងារធ្វើ។ មជ្ឈមណ្ឌលមួយចំនួនចាត់ទុកកុមារងាយ

រងគ្រោះ" ថា ជាប្រភពដែលអាចវាយតំលៃបានដោយស្រួលដែលពួកគេធ្វើការតាមលំនៅដ្ឋាន ប្រសិនបើពួកគេពុំបាន "ទទួល" អតិថិជននៃក្រុមគោលដៅដែលបានកំណត់អោយបានគ្រប់ចំនួនដូចដែលបានគ្រោងទុកនោះ ។ មានសមាមាត្រខ្ពស់ដែលទាក់ទងទៅនឹងអតិថិជនប្រភេទនេះដែលរស់នៅតាមលំនៅដ្ឋាននៅក្នុងមជ្ឈមណ្ឌលមួយចំនួន ។ អតិថិជនទាំងនេះមិនត្រូវការការពិគ្រោះផ្នែកចិត្តសាស្ត្រ ឬសេវាផ្នែកសង្គមដោយចាំបាច់នោះទេ ប៉ុន្តែពួកគេត្រូវការការបណ្តុះបណ្តាលជំនាញ ។ គំនិតនេះ គឺធ្វើឡើងតាមរយៈការរៀនជំនាញល្អៗ ដែលធ្វើឱ្យពួកគេនឹងអាចបោះបង់ការងារដែលប្រកបដោយគ្រោះថ្នាក់នោះចោល ។ ហេតុដូច្នេះហើយ យើងហៅកុមារប្រភេទនេះថាជា អតិថិជនគ្មានជំនាញ ហើយត្រូវការការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ប៉ុន្តែគួរឱ្យសោកស្តាយ ដែលមជ្ឈមណ្ឌលបានបែងចែកអតិថិជនរបស់ខ្លួនដោយមិនកំណត់ពីតំរូវការ និងសេវាទេ តែកំណត់ទៅលើក្រុមគោលដៅក្នុងវដ្តនៃការអភិវឌ្ឍន៏ទៅវិញ ។ នោះជាហេតុដែលយើងរកឃើញ "កុមារត្រូវជួញដូរ" ក្នុងចំណោមដែលបានចុះបញ្ជីរ ទោះបីក្រុមនេះធ្វើឡើងនូវប្រភេទខុសគ្នាបន្តិចក៏ដោយ ដែលក្រុមប្រភេទនេះត្រូវធ្វើឡើងដូចជា: ត្រូវគេជួញដូរឱ្យធ្វើជាពលករ ជួញដូរដោយកេងប្រវ័ញ្ចអោយបំរើផ្លូវភេទ អោយធ្វើជាអ្នកសុំទានជាដើម ។ "កុមារដែលត្រូវគេរំលោភបំពាន" គឺជារឿងមួយផ្សេងទៀតដែលត្រូវគេប្រើសំរាប់ជាការកេងយកប្រយោជន៏ ប៉ុន្តែមិនបានចង្អុលបង្ហាញពីការថែទាំ ឬបំរើសេវាដែលកុមារទាំងនេះត្រូវការឡើយ ។ មជ្ឈមណ្ឌលជាច្រើនបានចែករំលែកបទពិសោធន៍ដល់អ្នកដ៏ទៃ ដែលហាក់ដូចជាមិនផ្អែកលើប្រយោជន៏ពីអតិថិជនរបស់ខ្លួនឡើយ ។ មានមជ្ឈមណ្ឌលមួយចំនួនតូចទៀតដែលផ្តល់ជម្រកដល់ក្មេងប្រុសៗ ខណៈដែលមជ្ឈណ្ឌលភាគច្រើនអោយតែក្មេងស្រីស្នាក់នៅប៉ុណ្ណោះ ។ មជ្ឈមណ្ឌលខ្លះផ្តល់ជម្រកសំរាប់តែស្ត្រី ឬក្មេងស្រី ឬតែក្មេងប្រុសប៉ុណ្ណោះ ។ យើងមិនបានរកឃើញមជ្ឈមណ្ឌល ណាដែលផ្តល់ជម្រកសំរាប់កុមារទាំងពីភេទឡើយនៅពេលយើងចុះទៅ[៣] ។ តើនេះមានន័យថាមានតែកុមារប្រុស តិចតួចប៉ុណ្ណោះឬដែលត្រូវការសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាព? តាមការពិតអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ជាពិសេសអង្គការដែលកំណត់គោលដៅក្មេងប្រុសហាក់ដូចជាចង្អុលបង្ហាញថាវាមិនមែនដោយសារចំនួននោះទេ តែដោយសាតែយេនឌ័រ ដែលជាហេតុផលធ្វើឱ្យបែងចែកដូចនេះ ។ បុគ្គលិកជាច្រើនមកពីមជ្ឈមណ្ឌលដែលបានចុះមើលបានពន្យល់ថា វាមិនមែនជាវប្បធម៌សមរម្យទេ ដែលផ្តល់ទីជម្រកដល់ក្មេងប្រុស និងក្មេងស្រីជំទង់ៗ ដែលមិនមែនជាបងប្អូន

[៣] មជ្ឈមណ្ឌលស្តារលទ្ធភាពកុមារក្នុងស្រុក ផ្តល់ជម្រកអោយកុមារដែលត្រូវរំលោភបំពាន ឬមិនយកចិត្តទុកដាក់ដែលបានចុះទៅមើល យ៉ាងហោចណាស់ពីរដងពីខែឧសភា ឆ្នាំ ២០០២ ដល់ខែមិថុនា ឆ្នាំ ២០០៣ ។ មជ្ឈមណ្ឌលមួយចំនួនស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការអន្តរជាតិត្រូវបានចុះទៅមើលផងដែរ ។ ប៉ុន្តែមានមជ្ឈមណ្ឌលមួយចំនួន យើងមិនបានស្រាវជ្រាវ ព្រោះទើបបង្កើតឡើងបន្ទាប់ពីខែមករា ឆ្នាំ ២០០២ ឬមិនត្រូវបានទទួលស្គាល់ជាផ្លូវការដោយក្រសួងសង្គមកិច្ច ឬមិនបានចុះឈ្មោះជាមួយក្រសួងមហាផ្ទៃ ។ មជ្ឈមណ្ឌលជួយកុមារអនាថាមិនត្រូវបានចុះទៅមើលឡើយ ។

បង្កើតអោយនៅក្នុងគ្រឹះស្ថានតែមួយនោះ។ តាមពិតនៅក្នុងមជ្ឈមណ្ឌលបីដែលយើងរកឃើញថា មានក្មេងស្រី និងក្មេងប្រុសជំទង់ៗ ប៉ុន្តែពួកគេត្រូវតែផ្តល់ជម្រកដោយឡែកជារបៀបគ្រួសារ។ គ្រួសារទាំងនេះ គឺគ្មានផ្ទះសម្បែង លែងលះគ្នា ឬគេចចេញពីការប្រើអំពើហឹង្សាក្នុងគ្រួសារ។ ប៉ុន្តែ យើងមានចំណាប់អារម្មណ៍ថា នេះមិនមែនជាអំណះអំណាងសមរម្យទេដែលយកវប្បធម៌ជាលេស ហើយថាជាហេតុផលចំបងនោះបញ្ហាទូទៅនិងពិតប្រាកដនោះគឺជាកត្តាដែលទាក់ទងទៅនឹងម្ចាស់ជំនួយដែលនាំអោយក្មេងប្រុសជំទង់ៗមិនត្រូវតែឱ្យស្នាក់នៅ។

## ការថែទាំសមរម្យ

កុមារដែលត្រូវគេរំលោភ មិនត្រូវគេអើពើ ឬកុមារគ្មានជំនាញត្រូវការការថែទាំអោយបានល្អ ទោះបីជាប្រភេទបញ្ហាខុសគ្នាក៏ដោយ។ មជ្ឈមណ្ឌលស្តារលទ្ធភាពកុមារព្យាយាមដាក់ជំនួសឪពុកម្តាយ ហើយអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានរៀបចំជានីតិវិធី ដែលធានាអោយមានការថែទាំសមរម្យ។ នៅវេទិកាប្រជុំប្រចាំខែបុគ្គលិកមជ្ឈមណ្ឌលបានធ្វើការពិភាក្សាពីបញ្ហានៃការថែទាំតាំងពីខែឧសភា ឆ្នាំ ២០០២ និងបានឈានដល់កិច្ចព្រមព្រៀងជាទូទៅអំពីអ្វីដែលត្រូវចាត់ទុកថា ជាការថែទាំសមរម្យ[៤] នោះ។ ទស្សនះរបស់គេត្រូវគេប្រើជាការដាក់បញ្ចូលសំរាប់អង្គសិក្ខាសាលាថ្នាក់ជាតិស្តីពីការគ្រប់គ្រងមណ្ឌលកុមារ និងបទដ្ឋានអប្បបរមាដែលរៀបចំឡើងដោយ COSECAM នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០០៣។ របាយការណ៍ស្តីពីអង្គសិក្ខាសាលានេះ បង្ហាញពីកិច្ចព្រមព្រៀងថ្នាក់ជាតិលើបញ្ហា[៥] នេះ។ ទោះបីជាមានអ្នកចូលរួមមកពីគ្រប់មជ្ឈមណ្ឌលស្តារលទ្ធភាពកុមារក្នុងប្រទេសយ៉ាងណាក៏ដោយក៏ ពុំមានមជ្ឈមណ្ឌលណាមួយក្នុងចំណោមមណ្ឌល ដែលមានវត្តមានប្រលងជាប់តេស្តស្តីពីមូលដ្ឋាននៃបទដ្ឋានអប្បបរមាដែលបានស្នើឡើងនោះទេ។ តាមពិតមណ្ឌលមានបំណងធ្វើការសង្កេតលើបទដ្ឋានដែលពួកគេបានបង្កើត ប៉ុន្តែពួកគេត្រូវធ្វើដំណើរវែងឆ្ងាយមុននឹងរឿងនេះក្លាយជាការពិត។

តាមពិតមណ្ឌលស្ទើរទាំងអស់ផ្អែកលើបទពិសោធន៍ និងមនោសញ្ចេតនានៃបុគ្គលិករបស់ខ្លួនពេលដែលដោះស្រាយបញ្ហានៃការថែទាំ។ ការចុះទៅដោយផ្ទាល់របស់យើងមិនបានគ្រោងរកអោយឃើញពីបុព្វហេតុនៃការថែទាំមិនត្រឹមនោះទេ តែលទ្ធផលនៃការស្ទាបស្ទង់របស់អង្គការអាដហុកនៅឆ្នាំ ២០០៣ ក្នុងចំនោមគ្រឹះស្ថានមួយចំនួនតូចជាបុព្វហេតុនៃការព្រួយបារម្ភមួយចំនួន[៦]។ ការព្រួយបារម្ភនេះមិននិយាយដោយផ្ទាល់អំពីបញ្ហារំលោភបំពានដោយបុគ្គលិកមជ្ឈមណ្ឌលឡើយ ទោះបីជារឿងនេះបានកើតឡើងក្នុងអតីតកាលក៏ដោយ ដោយសារតែ

---

[៤] វេទិកាធ្វើជាម្ចាស់ដោយ COSECAM ប៉ុន្តែរបៀបវារៈត្រូវកំណត់ដោយឯករាជ្យដោយអ្នកចូលរួម។ មើល Dralf Minimum Standard សំរាប់ទីជម្រក ២០០៣ COSECAM របាយការណ៍ នរ. ០០៣អឺ

[៥] ស្តង់ដារអប្បបរមាសំរាប់ការថែទាំជំនួសនៅតាមមណ្ឌល ២០០៣ COSECAM របាយការណ៍ នរ. ០០៥

[៦] ក្រដាសពង្រាងស្តីអំពីជម្រកនៅតំបន់ក្រុងភ្នំពេញ ផ្នែកស្ត្រី ខែកញ្ញា ២០០៣ អង្គការអាដហុក

រឿងនេះជារឿងកម្រមាន ហើយវិធានការក៏ត្រូវដោះស្រាយ[៧] ហើយដែរ។ ការបារម្ភនៅក្នុងរបាយការណ៍របស់អង្គការអាដហុកនិយាយអំពីគោលនយោបាយរបស់អង្គការក្រៅរដ្ឋាភិបាលដោយគិតលើតួនាទីរបស់គេ គុណភាពនៃការថែទាំនឹងឥរិយាបទ និងការប្រតិបត្តិសមរម្យរបស់បុគ្គលិកមជ្ឈមណ្ឌល។ ក្រុមមួយដែលមានក្មេងស្រី ១៧នាក់ មកពីមណ្ឌលចំនួន៦មិនពេញចិត្តនឹងការប្រតិបត្តិ និងឥរិយាបទ[៨] មួយចំនួន។ បុគ្គលិកនៃមណ្ឌលមួយចំនួនទៀតហាក់ដូចជាចាត់ទុកក្មេងស្រីដែលត្រូវគេបង្ខំអោយធ្វើការជាពេស្យាចារជាពលរដ្ឋតូចទាប។ ក្មេងស្រីបានត្អូញត្អែរថាត្រូវតែធ្វើកិច្ចការកំប៉ិកកំប៉ុកនៅ តាមផ្ទះនៅគ្រាដែលក្មេងដទៃទៀតត្រូវគេផ្តល់ឱកាសអោយរៀនសូត្រ ឬបានសំរាក។ ការស្ទាបស្ទង់របស់អង្គការអាដហុកបង្ហាញ ពីការអនុវត្តផងដែរថាក្មេងស្រីដែលបានលើកឡើងឱ្យឈ្មោះថាចាក់សោរបង្ខាំងអតិថិជនរបស់គេ។ ចំពោះបញ្ហានេះ ទាំងគោលនយោបាយរបស់អង្គការក្រៅរដ្ឋាភិបាល ទាំងឥរិតាបទរបស់បុគ្គលិកត្រូវទទួលខុសត្រូវលើការថែទាំ។ គោលនយោបាយត្រូវរៀបចំឡើងដើម្បីចៀសវាងកុំអោយក្មេងស្រីរត់ចេញ ចំណែកឯឥរិយាបទរបស់បុគ្គលិកគឺជាបញ្ហាលើផ្លូវអារម្មណ៍ដែលធ្វើអោយអតិថិជនមិនគោរព។ វាគួរអោយចាប់អារម្មណ៍ផងដែរថាបុគ្គលិកមជ្ឈមណ្ឌលមួយចំនួនមិនចង់អោយក្មេង ដែលរងនូវការរំលោភផ្លូវភេទនិយាយអំពីបទពិសោធន៍អតីតកាលរបស់គេ-ពួកគេបាននិយាយថា នេះគឺជាការបើកនូវក្តីឈឺចាប់។ នៅពេលដែលត្រូវសួរថា តើពួកគេដឹងរឿងនេះយ៉ាងដូចម្តេចបុគ្គលិកភាគច្រើនឆ្លើយថានេះជាចំណេះដឹងទូទៅ។ តាមពិតឥរិយាបទរបស់គេមានអារម្មណ៍ថាអ្វីដែលបានកើតឡើងចំពោះកុមារគឺគួរអោយអៀនខ្មាស់ហើយកុមារនោះហើយដែលរងនូវការស្តីបន្ទោសទាំងនេះ។ បើមិនអញ្ចឹងទេយ៉ាងហោចណាស់អ្នកឯទៀតចាត់ទុកកុមារទាំងនោះគួរអោយខ្មាស់អៀន។ ប៉ុន្តែមានក្មេងស្រី ១៧នាក់ បាននិយាយពីបញ្ហាផ្ទាល់ខ្លួនដោយត្រង់ៗថា ពួកគេចង់និយាយអំពីអ្វីដែលបានកើតឡើងចំពោះរូបគេ។ ការអនុវត្តដែលគួរឱ្យព្រួយបារម្ភមួយទៀតនោះគឺ ការដាក់អតិថិជនឱ្យនៅឯកកោពីញាតិសន្តានរបស់គេ សំណាងហើយដែលរឿងនេះមិនលេចឮខ្ទរខ្ទាយទៅខាងក្រៅ។ ហេតុផលនេះគឺថាបទដ្ឋានអប្បបរមាសំរាប់ការថែទាំនៅតាមមណ្ឌល គឺត្រូវបញ្ចូលការរៀបចំឱ្យមានការទំនាក់ទំនងជាមួយនឹងញាតិសន្តាននៅពេលចាំបាច់ បើសិនអតិថិជនមិនចង់ជួបពួកគេ។

បញ្ហានៃការថែទាំសមរម្យមិនត្រូវបានដោះស្រាយព្រោះមិនទាន់មានបទដ្ឋានរអប្បបរមា ឬការងាររបស់បុគ្គលិកដែលមានសមត្ថភាព។ មជ្ឈមណ្ឌលត្រូវការអោយមានគោលនយោបាយល្អដោយផ្អែកលើផលប្រយោជន៍របស់អតិថិជនខ្លួន។ ផលប្រយោជន៍ នេះតំរូវឱ្យមជ្ឈមណ្ឌលធ្វើសហប្រតិបត្តិការអោយជិតស្និត និងចៀសវាងនិន្នាការត្រួតត្រា។ គួរឱ្យសោកស្តាយដែលផលប្រយោជន៍របស់អតិថិជន ជានិច្ចជាកាលមិនត្រូវអោយជាអាទិភាព

[៧] ករណីមួយចំនួនត្រូវរាយការណ៍ក្នុងប្រព័ន្ធឃោសនាអំពីនាយកអង្គការដែលបានប្រព្រឹត្តមិនគប្បី ហើយត្រូវបានគេដកចេញពីដំណែងជាបន្តបន្ទាប់។

[៨] លក់ដូចសត្វមាន់ ២០០៣ COSECAM របាយការណ៍ នរ. ០០៦

លើផលប្រយោជន៍របស់អង្គការឡើយ។ ដំណើររបស់អង្គការ គឺទទួលមូលនិធិ និងផលប្រយោជន៍ផ្ទាល់ខ្លួនរបស់បុគ្គលិកដូចជាមាន ឬរក្សាការងារពោលគឺ ជាការលើកទឹកចិត្តដើម្បីមើលអោយឃើញពីផលប្រយោជន៍ពិតប្រាកដរបស់អតិថិជនប្រសិនជម្លោះផលប្រយោជន៍ទាំងនេះជាមួយនឹងផលប្រយោជន៍រស់រានមានជីវិត ឬការងារ។

## តម្លៃ និងសីលធម៌

គ្រប់មណ្ឌលទាំងអស់ព្យាយាមហាត់ពត់លត់ដំអោយមានឥរិយាបទ និងអាកប្បកិរិយាល្អលើអតិថិជន។ ប៉ុន្តែវាហាក់ដូចជាបង្វែទៅរកការអប់រំឡើងវិញទៅវិញ។ ក្នុងន័យនេះ មិនគ្រាន់តែការសិក្សាពីសីលធម៌ និងតំលៃនិយាយសំរាប់ខ្លួនឯងប៉ុណ្ណោះនោះទេ ថែមទាំងជារបាយការណ៍ពីដំណើរការរបស់អង្គការក្រៅរដ្ឋាភិបាលមួយចំនួនដោយស្រាយបំភ្លឺពីមតិយោបល់របស់គេដែលក្មេងៗគួរតែរៀនពីតម្លៃ និងអាកប្បកិរិយា[៥] អោយបាន "សមរម្យ"។ នេះបញ្ជាក់អោយឃើញថាតម្លៃ និងអាកប្បកិរិយារបស់អតិថិជនបច្ចុប្បន្ននេះមិនទាន់សមរម្យនៅឡើយ។ តាមពិតពេលដែលយើងចុះទៅ យើងជាញឹកញាប់មានចំណាប់អារម្មណ៍ថា បុគ្គលិកមជ្ឈមណ្ឌលសន្មត់ថាឈ្មោះ "ស្រីខូច" (ស្ត្រីខូចចិត្ត) មានន័យថា ជាអតីតស្រីរកស៊ីផ្លូវភេទដោយឪពុកម្តាយចិញ្ចឹមបីបាច់មិនបានល្អ។ ការទំនាក់ទំនងរបស់យើងជាមួយអតិថិជនបែបនេះ យើងមិនរកឃើញភស្តុតាងថាតម្លៃ និងអាកប្បកិរិយារបស់គេមានលក្ខណៈខុសប្លែកពីកុមារកម្ពុជាដទៃទៀតដែលមានប្រវត្តិស្រដៀងគ្នាឡើយ។ តាមការពិតកុមារដែលធ្លាប់រស់នៅតាមផ្ទះបនពេស្យាចារ មិនសូវស្តាប់បង្គាប់ដូចក្មេងដែលរស់នៅជាមួយឪពុកម្តាយទេ។ ពួកគេមានភាពវៃឆ្លាតក្នុងការរស់នៅតាមថ្នល់ និងសមត្ថភាពយល់ដឹងពីបរិស្ថានថ្មីៗដែលនៅជុំវិញគេជាងកុមារធម្មតា។ ប៉ុន្តែរឿងនេះត្រូវដោះស្រាយបានតិចតួចណាស់នូវអ្វីដែលគេបានលើកឡើង។ ហេតុដូច្នេះហើយក្នុងករណីភាគច្រើនពុំមានហេតុផលអ្វីដែលត្រូវអប់រំពួកគេឡើងវិញឡើយ។ មានមជ្ឈមណ្ឌលជាច្រើនសន្មត់ថា ភារកិច្ចឪពុកម្តាយត្រូវតែបន្តចិញ្ចឹមកូនទៅតាមប្រព័ន្ធតម្លៃសង្គមរបស់គេ។ ការផ្តល់ជាមេរៀនអំពីអ្វីជាអាកប្បកិរិយា និងឬកពារល្អ ដែលសង្គមអាចទទួលយកបាន ហើយដែលនៅថ្ងៃណាមួយពួកគេនឹងវិលត្រឡប់មករកភាពល្អឡើងវិញ គឺជាភារកិច្ចដែលយើងទាំងអស់គ្នាកំពុងធ្វើ បើសិនណាមេរៀនទាំងនេះមិនមែនជារការបញ្ចូលមនោគមវិជ្ជាទេនោះ។

មជ្ឈមណ្ឌលទាំងអស់ពឹងផ្អែកការអប់រំរបស់ខ្លួនតាមគោលការណ៍ព្រះពុទ្ធសាសនា លើកលែងតែមណ្ឌលមួយចំនួនដែលប្រតិបត្តិតាមបែបព្រះយេស៊ូគ្រិស្ត។ មណ្ឌលដែលប្រតិបត្តិតាមបែបគ្រីសសាសនា បានបង្រៀនពីសីលធម៌ និងតម្លៃ ប៉ុន្តែនេះមិនបានដល់ប្រជាជនភាគច្រើននោះឡើយ។ ប្រហែលជាអាចឆ្លល់ថា បញ្ហានេះនឹងមានផលប៉ះពាល់អ្វីខ្លះក្នុងការធ្វើសមាហរណកម្មអតិថិជនទៅក្នុងសង្គមរបស់គេវិញនៅកម្ពុជា។ យើងគាំទ្រយ៉ាងពេញទំហឹងនូវយោបល់របស់ គណៈកម្មការធ្វើការលើក្របខណ្ឌច្បាប់សំរាប់មជ្ឈមណ្ឌលកុមារ និងការថែទាំជំនួស

[៥] សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ HCC, CWCC, CCPCR និងមជ្ឈមណ្ឌលផ្សេងៗទៀត

ដែលកុមារនៅក្នុងការថែទាំនៅតាមមណ្ឌល ត្រូវគេចិញ្ចឹមបីបាច់ទៅតាមប្រព័ន្ធតំលៃដែលត្រូវគេចិញ្ចឹម[១០] ។ នេះមានន័យថា ឧទាហរណ៍កុមារជាជាតិ **ចាម** គួររៀនពីសីលធមិ និងតម្លៃតាមបែបគោលការណ៍អ៊ីស្លាម ចំណែកឯកុមារចិញ្ចឹមតាមបែបសាសនាគ្រីស្តត្រូវរៀនទៅតាមតម្លៃសាសនាគ្រីស្ត។ កុមារមិនត្រូវបានដាក់ឱ្យរស់នៅកន្លែងដែលគេបង្ខំឱ្យជ្រើសរើសប្រព័ន្ធតម្លៃមួយផ្សេងទៀតឡើយ។ ការធ្វើដូច្នេះគឺជាការរំលោភសិទ្ធិដោយផ្ទាល់មួយក្នុងចំណោមសិទ្ធិកុមារចំបងៗ។ ទោះបីជាបុគ្គលិករបស់មជ្ឈមណ្ឌលដែលកាន់សាសនាគ្រីស្ត ធានាចំពោះយើងថា អតិថិជនរបស់ខ្លួនមានជម្រើសមិនចូលរួមបូជា ឬបួងសួងក៏ដោយ ក៏យើងនៅសង្ស័យចំពោះរឿងនេះថា មានការគាបសង្កត់តាមបែបបរិយាកាសសង្គមនៅក្នុងណ្ឌល ដូចនេះតាមការពិតទៅតិថិជនមានមានជំរើសតិចតួចណាស់[១១] ។ ប៉ុន្តែបញ្ហានេះ បានត្រូវគេចាប់អារម្មណ៏ច្រើនចំពោះតែមជ្ឈមណ្ឌលថែទាំកុមារ ដែលមិនមែនតាមបែបព្រះពុទ្ធសាសនា ដោយសារតែមណ្ឌលកម្រទទួលកុមារ ដែលមកពីប្រព័ន្ធតម្លៃផ្សេងៗទៀតក្រៅពីប្រព័ន្ធបែបព្រះពុទ្ធសាសនាណាស់[១២] ។

## ការអប់រំ

មជ្ឈមណ្ឌលទាំងអស់បង្រៀនអោយចេះអានចេះសរសេរ ហើយភាគច្រើនបណ្តុះបណ្តាលវិជ្ជាជីវៈទៅឱ្យអតិថិជន។ នេះគឺជាវិធានការដ៏ល្អជាពិសេសចំពោះកុមារជាច្រើនដែលមិនមានឱកាសចូលសាលា ហើយអោយពួកគេរៀនអាន រៀនសរសេរ ឬរៀនជំនាញអាជីព។ វាក្លាយទៅជាការព្រួយបារម្ភមួយ ពេលដែលមេរៀននេះត្រូវគេប្រើជាមធ្យោបាយដើម្បីបញ្ចូលមនោគមវិជ្ជាដល់អតិថិជន។ ឧទាហរណ៍ មានមជ្ឈមណ្ឌលមួយ ដែលការបង្រៀនរបស់គេគឺមិនត្រឹមតែផ្ដើលើគោលការណ៍សាសនាទេ ប៉ុន្តែថែមទាំងភ្ជាប់ដោយផ្ទាល់ទៅនឹងសាសនា ហើយនេះប្រហែលជាមិនមានតែមណ្ឌលតែមួយនោះឡើយ។ ប្រភពដែលអាចជឿជាក់បានរាយការណ៍អំពីមជ្ឈមណ្ឌលមួយដែលមាន "ប្រាំព្រឹកក្នុងមួយសប្តាហ៍ ក្មេងស្រីចូលរួមធ្វើសមាធិដែលរួមទាំងការធ្វើសក្ការបូជា ការបង្រៀន

---

[១០] គណៈកម្មាធិការក្របខណ្ឌច្បាប់ដែលមានតំណាងមកពីក្រសួងសង្គមកិច្ច, ក្រសួងយុត្តិធមិ, អង្គការ Unicef, IOM, COSECAM, ក្រុមសុខមាលភាពកុមារ និងក្រុមផ្សេងទៀត។ គណៈកម្មការទទួលស្គាល់ដោយក្រសួងសង្គមកិច្ចជាក្រុមប្រឹក្សាយោបល់ទទួលបន្ទុកលើការថែទាំជំនួសកុមារ។

[១១] មិនទាន់ចេញលទ្ធផលមកពីការសិក្សានូវកត្តាតំរូវការលើការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅឡើយជាយថា ទស្សនីរបស់អ្នកធ្វើការនៅមូលដ្ឋានធ្វើឡើងដោយ ECR កម្ពុជា។

[១២] ទិន្នន័យស្ថិតិអំពីសាសនារបស់អតិថិជននាពេលថ្មីៗនេះមិនអាចរកបាន ហើយភាគច្រើនមជ្ឈមណ្ឌលស្តាលទ្ធភាពមិនបានកត់ត្រាទុក។ ប៉ុន្តែទិន្នន័យមានសារៈសំខាន់ណាស់ដើម្បីវាយតំលៃ ប្រសិនបើមានតំរូវការសំរាប់ការអប់រំតំលៃតាមបែបមិនមែនព្រះពុទ្ធសាសនា។ ហេតុផលនេះសំរាប់តែទំរង់ទិន័យពតិមានរបស់ COSECAM លើអ្នករស់រានមានជីវិតនៃការកេងប្រវ័ញ្ចផ្លូវភេទ រួមទាំងបញ្ហាសាសនារបស់អតិថិជន។

គម្ពីរ និងបួងសួង។ នៅក្នុងគ្រប់សមាសភាពទាំងអស់ (ការបណ្តុះបណ្តាលវិជ្ជាជីវៈ, ការអប់រំ, សុខភាព, និងការពិគ្រោះយោបល់) គម្ពីរសាសនា និងតម្លៃសាសនាគ្រីស្តត្រូវគេដាក់បញ្ចូលទៅក្នុងមេរៀន។ ឧទាហរណ៍ អ្នកបណ្តុះបណ្តាលវិជ្ជាជីវៈប្រើគម្ពីរសាសនាបង្រៀនពីក្រមសីលធម៌ការងារ និងអ្នកធ្វើការសង្គមកិច្ច និងបុគ្គលិកពេទ្យនឹងបួងសួងអោយមានអារម្មណ៍ និងផ្លូវកាយស្ងប់។ នៅពេលល្ងាចជាញឹកញាប់ត្រូវសុំអោយម្តាយនៅឯផ្ទះនាំពួកគេទៅធ្វើសក្ការ និងបួងសួងសំរាប់ការសិក្សារបស់គេ។ លើសពីនេះទៀតក្មេងស្រីទៅព្រះវិហារនៅតាមវិហារមូលដ្ឋានជារៀងរាល់សប្តាហ៍ ហើយបញ្រ្ជាបពួកគេបន្តិចម្តងៗទៅក្នុងជីវិតព្រះវិហារ[១៣]។ នេះបញ្ជាក់យ៉ាងច្បាស់ថាកុមារពុំមានជម្រើសណាមួយដោយសារតែ "តម្លៃសាសនាយេស៊ូគ្រីស្តត្រូវគេបញ្រ្ជាប" ទៅលើការអប់រំ។ មានការឯកភាពទូទៅមួយក្នុងចំណោមបុគ្គលិកមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារដែលថា ការប្រតិបត្តិបែបនេះមិនត្រូវបានគេអនុញ្ញាតអោយឡើយ ប្រសិនបើវាធ្វើអោយពាក់ព័ន្ធដល់កុមារដោយផ្អែកលើប្រពៃណីសាសនាផ្សេងទៀត[១៤]នោះ។ ក្រៅពីនេះ វាគឺជាការរំលោភបំពានដោយផ្ទាល់លើច្បាប់ប្រទេសកម្ពុជាដែលហាមឃាត់មិនអោយមានការញុាំងដែលនាំអោយមានការផ្លាស់ប្តូរសាសនា។ សមាជិករបស់គណៈកម្មការ ដែលធ្វើការលើការថែទាំជំនួសបាននិយាយពីស្ថានភាពកន្លែង ដែលក្មេងៗត្រូវគេដាក់ពិន័យនៅពេលដែលពួកគេនិយាយភាសាកំណើត[១៥]។ ហេតុផលអាចមិនសមប្រម្យដូចជា ការព្យាយាមផ្លាស់ប្តូរកុមារអោយទៅកាន់សាសនាមួយផ្សេងទៀត ឬពួកគេអាចមានចេតនាបញ្រ្ជាបមនោគមវិជ្ជាតាមរយៈកម្មវិធីសិក្សាភាសា។ យ៉ាងណាក៏ដោយមតិទូទៅក្នុង ចំណោមអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធនិយាយថា វាជាការប្រតិបត្តិខុស។ មជ្ឈមណ្ឌលមួយចំនួនមានគោលនយោបាយបញ្ជូនកុមារដែលមានអាយុគ្រប់អាចចូលសាលាទៅរៀននៅសាលារដ្ឋ។ មជ្ឈមណ្ឌលទាំងអស់មិនសុទ្ធតែយល់ស្របនឹងការប្រតិបត្តិនេះទេដោយសារពួកគេមានការភ័យខ្លាចនឹងផលប៉ះពាល់អវិជ្ជមានពីកុមារ និងគ្រូនៅសាលា។ ប៉ុន្តែយើងគិតថាដំណើរការសមាហរណកម្មត្រូវតែចាប់ផ្តើមពីឥឡូវនេះទៅ ដែលកុមារចូលមកមជ្ឈមណ្ឌលដូចជាឱ្យទៅសាលារដ្ឋហាក់ដូចជាការចាប់ផ្តើមល្អមួយ។ តាមការពិតមជ្ឈមណ្ឌលត្រូវចាត់វិធានការអោយកុមារមានអារម្មណ៍សុវត្ថិភាពនៅតាមផ្លូវទៅសាលានិងនៅក្នុងសាលា។ បទដ្ឋានអប្បបរមាសំរាប់ការថែទាំតាមមណ្ឌលបានបង្ហាញនៅពេលមានអង្គសិក្ខាសាលារបស់ក្រសួងសង្គមកិច្ចស្តី អំពីការថែទាំកុមារសំនួសនៅខែតុលា ២០០៣ ដោយលើកឡើងពីបញ្ហា[១៦]នេះ។ គោលបំណងនៃការបណ្តុះបណ្តាលជំនាញនេះគឺ ដើម្បីធ្វើឱ្យអតិថិជនអាចស្វែង

---

[១៣] កុមារ និងការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចកុមារចំពោះគោលការណ៍ណែនាំហានីភ័យៈ Volume 4, Miles and Stephen, 2000, Tearfund (P.53).

[១៤] សូមមើលការពិភាក្សារបស់ក្រុមផ្តល់ជម្រកវេទិកាសំរាប់កិច្ចប្រជុំរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពកុមាររៀងរាល់ថ្ងៃទី ១៥ ប្រចាំខែដើម្បីពិភាក្សានូវបញ្ហាដែលពាក់ព័ន្ធទូទៅ (ទំនាក់ទំនងលោក អ៊ុំ រតនា នៅ COSECAM សំរាប់ព័ត៌មានបន្ថែម)។

[១៥] គណៈកម្មការក្របខណ្ឌនិយ័តកម្មប្រជុំនៅខែឧសភា ២០០៣។

[១៦] បទដ្ឋានអប្បបរមាសំរាប់ការថែទាំតាមមណ្ឌល ២០០៣ COSECAM របាយការណ៍ នរ.០០៥។

រកការងារល្អ ឬអាចចាប់ផ្តើមបើកអាជីវកម្មរបស់ខ្លួន។ មានការពិភាក្សាអំពីការប្រើប្រាស់ជំនាញដូចជា ការព្យាបាលផ្លូវចិត្ត ហើយជាញឹកញាប់មានផលប៉ះពាល់ ប៉ុន្តែគ្មានមជ្ឈមណ្ឌលណាមួយចុះទៅមើលការបង្ហាញនូវការប្រើប្រាស់ទំរង់នៃការព្យាបាលនេះឡើយ។ នេះត្រូវតែរំពឹងសព្វថ្ងៃមានការខ្វះខាតនូវអ្នកធ្វើការ និងអ្នកពិគ្រោះយោបល់ផ្នែកសង្គមដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ។ មានមជ្ឈមណ្ឌលពីរដែលមានមោទនភាពខ្លួនឯងដោយប្រើប្រាស់នូវការរៀនជំនាញជាក់លាក់ជាទំរង់នៃការព្យាបាលរួមទាំងការងារបណ្តុះបណ្តាលដែលទាក់ទង ប៉ុន្តែយើងមិនត្រូវបានអនុញ្ញាតដើម្បីអង្កេតលើការបណ្តុះបណ្តាលនេះឡើយ ហើយយើងមិនបានទទួលឯកសារដែលបង្ហាញពីវិធីព្យាបាលនោះឡើយ។ ទោះបីយ៉ាងណាក៏ដោយ បញ្ហានេះនៅតែមានសារៈសំខាន់នៅក្នុងរបាយការណ៍នេះ យើងនឹងធ្វើការពិភាក្សាតែបណ្តុះបណ្តាលជំនាញជាការរៀបចំសំរាប់ការងារ ហើយមិនពិភាក្សាពីការអនុវត្តន៍វិធីព្យាបាលរបស់ខ្លួនឡើយ។

## ការបណ្តុះបណ្តាលជំនាញ

ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈមានរូបរាងជាច្រើនសណ្ឋាន។ ទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ដោយបុគ្គលិកមជ្ឈមណ្ឌលទៅកាន់មជ្ឈមណ្ឌលទៅវិញទៅមក ដោយផ្តល់នូវព័ត៌មានជាក់លាក់អំពីការបណ្តុះបណ្តាលជំនាញនៅតាមមជ្ឈមណ្ឌលមួយចំនួន[១៧]។ ពួកគេបានចុះសួរសុខទុក្ខមជ្ឈមណ្ឌលចំនួន ១៣ មិនមានតែនៅក្រុងភ្នំពេញប៉ុណ្ណោះទេ រួមទាំងមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារភាគច្រើនស្ថិតនៅតាមខេត្តនានា។ ការសន្និដ្ឋានជាទូទៅគឺថា មានមជ្ឈមណ្ឌលជាច្រើនបានផ្តល់នូវការបណ្តុះបណ្តាលដូចៗគ្នា ឧទាហរណ៍ ការដេរ តម្បាញ និងបានបើកវគ្គស្រដៀងៗគ្នា ឧទាហរណ៍ កំរិតមូលដ្ឋានដែលជាញឹកញាប់រៀនមួយពេល គឺនៅពេលព្រឹក ឬពេលរសៀល (ហេតុដូច្នេះហើយមិនមែនរៀនពេញមួយថ្ងៃនោះឡើយ)។ វគ្គបណ្តុះបណ្តាលមានរយៈពេលពី ៣ខែ ទៅ ៦ខែ។ មាននិន្នាការ ១ នៅក្នុងចំនោមមជ្ឈមណ្ឌលទាំងនោះបណ្តុះបណ្តាលជំនាញច្រើនប្រភេទ ដូចជាជំនាញកសិកម្ម អ៊ុតសក់ បំរើសេវាម្ហូបអាហារ ឬរៀនពីរបៀបចំអិនអាហារនៅតាមភោជនីយដ្ឋាននៅក្នុងវគ្គបណ្តុះបណ្តាលរបស់ពួកគេ។ មជ្ឈមណ្ឌលមួយចំនួនមានការរីកចំរើនទៅមុខគួរឱ្យកត់សំគាល់ ខណៈដែលមណ្ឌលផ្សេងទៀតកំពុងតែដកបទពិសោធន៍។ ប៉ុន្តែទោះបីជាមជ្ឈមណ្ឌលផ្តល់វគ្គបណ្តុះបណ្តាលដែលមានប្រភេទផ្សេងៗគ្នាយ៉ាងណាក៏ដោយ ក៏អតិថិជនរបស់គេជាញឹកញាប់មានជំរើសតិចតួចណាស់ ដោយសាតែការចុះឈ្មោះចូលរៀនយឺត ឬកន្លែងមានកំណត់សំរាប់វគ្គមួយៗ។ ដូច្នេះយើងអាចធ្វើការវាយតំលៃបានថា មិនមានមជ្ឈមណ្ឌលណាមួយផ្តល់ការបណ្តុះបណ្តាលលើសពីកំរិតមូលដ្ឋានឡើយ។ វាតម្រូវអោយមានការវាយតំលៃជាពិសេសដោយអ្នកវិជ្ជាជីវៈថែមទៀត

[១៧] ការផ្លាស់ប្តូរទស្សនកិច្ចសិក្សាតាមមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារ ២០០៣ COSECAM របាយការណ៍ នរ.០០៤ (ភាសាអង់គ្លេស និងខ្មែរ)

ដើម្បីឆ្លើយតបទៅនឹងបញ្ហានៃគុណភាព និងវិធីសាស្ត្រនៃវគ្គបណ្តុះបណ្តាលដែលត្រូវផ្តល់អោយ[១៨]។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ការវាយតំលៃរបស់យើងអាចជាធនធានមួយសំរាប់យកមកពិភាក្សាលើទិដ្ឋភាពមួយចំនួនទៀតនៃការបណ្តុះបណ្តាលជំនាញស្តីពីការផ្តល់អោយនៅតាមមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារដែរ។

មជ្ឈមណ្ឌលមួយចំនួនអះអាងនៅក្នុងកម្មវិធីរបស់គេ ដើម្បីធ្វើការស្រាវជ្រាវផ្នែកទីផ្សារដើម្បីកំណត់រកជំនាញដែលជាតម្រូវការ។ យើងដឹងថាយ៉ាងហោចណាស់ក៏មានមជ្ឈមណ្ឌលពីរដែរ ដែលអនុវត្តវិធីសាស្ត្របែបនេះ។ មានមជ្ឈមណ្ឌលមួយធ្លាប់បានដំណើរការមណ្ឌលវិជ្ជាជីវៈដែលផ្តល់ម្ហូបអាហារទៅអោយកុមារក្រីក្រមិនចាំបាច់តែកុមារដែលជាជនរងគ្រោះដោយការរំលោភបំពាននោះទេ។ ទោះបីជាមជ្ឈមណ្ឌលនោះបានប្រព្រឹត្តល្អយ៉ាងណាក៏ដោយ ក៏អង្គការក្រៅរដ្ឋាភិបាលមួយចំនួនត្រូវតែបិទទ្វារដោយខ្វះមូលនិធិ[១៩]។ មជ្ឈមណ្ឌលទាំងពីរនេះបានប្រើលទ្ធផលស្រាវជ្រាវទីផ្សាររបស់ខ្លួន ដើម្បីកំណត់កញ្ចប់វគ្គបណ្តុះបណ្តាលជំនាញសំរាប់មណ្ឌលរបស់ពួកគេ។ ប៉ុន្តែយើងបានអានរបាយការណ៍ប្រចាំឆ្នាំ ២00៣ ថា មានក្មេងស្រីតិចជាង ៣0% ដែលទទួលការបណ្តុះបណ្តាលកំពុងប្រើជំនាញរបស់ខ្លួន ហើយអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ក្នុងការចិញ្ចឹមជីវិត[២0]។ របាយការណ៍នេះក៏បានចង្អុលផងដែរថា ចំនួនអតិថិជនយ៉ាងច្រើនចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន ប៉ុន្តែអត្រាជោគជ័យនៅទាបខ្លាំងណាស់។ មានសមាមាត្រអតិថិជនដែលស្វែងរកការងារធ្វើទទួលជោគជ័យតិចតួចក្នុងការទទួលបានការងារ និងអាចរក្សាការងាររបស់គេបាន។ ការបណ្តុះបណ្តាលជំនាញដែលមជ្ឈមណ្ឌលផ្តល់អោយ ទោះបីជាវិជ្ជាជីវៈហាក់ដូច ជាការកំណត់គោលដៅសហគ្រិនភាពតិចតួចទៅថ្ងៃខាងមុខក៏ដោយ។ មជ្ឈមណ្ឌលផ្សេងទៀតដែលក្រុមយើងបានចុះសួរសុខទុក្ខក៏បានរាយការណ៍ស្រដៀងគ្នានេះដែរ ឬភាពជោគជ័យមានកំរិតទាបជាងនេះទៅទៀត[២១]។ ពួកគេលើកហេតុផលប្រៀបដូចនឹងការប្រកួតប្រជែងជាមួយនឹងអាជីវកម្មខ្នាតតូចដែលមានស្រាប់ ផលិតផលមានគុណភាពទាប មិនមានតំរូវការទីផ្សារ ហើយជាញឹកញាប់ខ្វះជំនាញធ្វើអាជីវកម្ម។ ប្រហែលជាយើងឆ្ងល់ថា តើមានហេតុផលអ្វីខ្លះដែលធ្វើឱ្យលទ្ធផលនៃការបណ្តុះបណ្តាលវិជ្ជាជីវៈនៅមានកំរិតទាប។ អតិថិជនភាគច្រើន ដែលស្ថិតក្នុងប្រភេទ

---

[១៨] កម្មវិធីដោះដូរសួរសុខទុក្ខសំរាប់ឆ្នាំ ២00៣-២00៤ រួមទាំងដំបូន្មានដោយផ្អែកលើដំណោះស្រាយនេះ។ អ្នកបណ្តុះបណ្តាលមកពីមជ្ឈមណ្ឌលមួយចំនួននឹងចុះសួរសុខទុក្ខមជ្ឈមណ្ឌលមួយចំនួន ដែលផ្តល់អោយពួកគេសំរាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួនអោយរៀនប្រតិបត្តិអោយបានល្អ និងមេរៀនដែលបានរៀន។

[១៩] មណ្ឌល HCC ដែលបានបើកសាលាវិជ្ជាជីវៈក្នុងខេត្តព្រៃវែងក្នុងឆ្នាំ២00២។ មជ្ឈមណ្ឌលនេះទទួលពិន្ទុខ្ពស់ក្នុងការបណ្តុះបណ្តាលលើមតិយោបល់នៃបុគ្គលិកដែលចុះសួរសុខទុក្ខមកពីមជ្ឈមណ្ឌលផ្សេងៗទៀត (មើលរបាយការណ៍ COSECAM នរ.00៤) HCC បានទទួលជំនួយពីស្ថានទូតជប៉ុនដើម្បីស្ថាបនាមជ្ឈមណ្ឌលវិជ្ជាជីវៈនៅជិតក្រុងភ្នំពេញ។ ពួកគេមានបំណងផ្តល់វគ្គផ្សេងៗទៅឱ្យមជ្ឈមណ្ឌលអតិថិជនផ្សេងៗទៀត និងកុមារដែលគ្មានជំនាញ។

[២0] HCC របាយការណ៍ប្រចាំឆ្នាំ២00២។

[២១] ពតិមានទិន្ន័យមជ្ឈមណ្ឌលស្តាលទ្ធភាពកុមារ COSECAM.

ប្រជាជនក្រីក្របំផុត (ហេតុផលសំរាប់ពួកគេដើម្បីរកការងារ ហើយត្រូវគេបោក ឬជួញដូរអោយធ្វើជាពេស្យាចារ) ដោយមិនបានរៀនខ្ពង់ខ្ពស់ឬមិនបានរៀនសូត្រ ឬគ្មានជំនាញពិសេស។ ពួកគេមិនគ្រាន់តែជាអ្នកដែលងាយរងគ្រោះប៉ុណ្ណោះទេ តែថែមទាំងពួកគេខ្វះការទំនាក់ទំនងទៅនឹងវដ្តអាជីវកម្ម ឬបទពិសោធន៍ក្នុងការធ្វើអាជីវកម្មថែមទៀត។ ដូច្នេះហេតុអ្វីបានជាគេសន្មត់ថា ក្រុមនេះមានឱកាសល្អដើម្បីទទួលជោគជ័យ ខណៈដែលអ្នកផ្សេងមានការអប់រំ និងការទំនាក់ទំនងល្អបែរជាញឹកញាប់ទទួលបរាជ័យ? នេះវាបានបង្ហាញយ៉ាងច្បាស់ថាមជ្ឈមណ្ឌលស្តារលទ្ធភាពជម្រុញអោយមានការផ្តួចផ្តើមសហគ្រិនភាពទាំងនេះឡើងដោយសារមានជម្រើសការងារតិចតួច។ ប៉ុន្តែការងារហាក់ដូចជានៅតែមានជម្រើសប្រសើរសំរាប់អតិថិជនជាច្រើននៅទីបញ្ចប់ ដោយផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវនឹងជំនាញនិងបទពិសោធន៍ដែលនិយោជកត្រូវការ។

## ការបណ្តុះបណ្តាលសំរាប់ការងារ

វាជាចំណេះដឹងទូទៅ ហើយត្រូវបញ្ជាក់តាមប្រវត្តិរូបសង្ខេបលើអតិថិជនដែលភាគច្រើនជាក្មេងស្រីដែលមានអាយុពី ១៥ ទៅ ១៨ឆ្នាំ ត្រូវគេអនុញ្ញាតឱ្យចូលទៅមជ្ឈមណ្ឌលមានចំណេះដឹងទាប ឬមិនដែលចូលសាលា។ អ្នកទាំងនោះមិនចេះអាន ឬសរសេរនៅពេលពួកគេចូលមកដំបូង។ ភាគច្រើនពួកគេពុំមានបទពិសោធន៍ការងារ។ គ្មាននរណាម្នាក់មានជំនាញធ្វើអាជីវកម្មឡើយ។ ទោះបីមានគុណវិបត្តិទាំងនេះក៏ដោយ ក៏មជ្ឈមណ្ឌលផ្តល់ការបណ្តុះបណ្តាលជំនាញក្នុងគោលបំណងរៀបចំក្មេងទាំងនោះឱ្យមានទីផ្សារការងារ ឬចាប់ផ្តើមអាជីវកម្មខ្នាតតូច។ ក្នុងករណីមួយចំនួនមជ្ឈមណ្ឌលបានចុះកិច្ចសន្យាជាមួយរោងចក្រ ឬក្រុមហ៊ុនដើម្បីអោយទទួលអតិថិជនបន្ទាប់ពីពួកគេបានបញ្ចប់ការបណ្តុះបណ្តាលរបស់គេជាកូនជាងរួចមក។ ឧទាហរណ៍ មជ្ឈមណ្ឌលស្តារលទ្ធភាពកុមារក្នុងព្រៃនប់ ក្រុងកំពង់សោមអាចបញ្ជូនក្មេងស្រីអោយទៅធ្វើការនៅរោងចក្រកាត់ដេរក្នុងក្រុង។ ប៉ុន្តែរោងចក្រទាំងនេះមានតំរូវការពិសេស ហើយជាញឹកញាប់អតិថិជនពុំមានជំនាញគ្រប់គ្រាន់ដែលអាចទទួលយកបានឡើយ។ ក្រៅពីនេះមានក្មេងស្រីជាច្រើនដែលបានរៀនជំនាញដូចៗគ្នា ហើយពួកគេត្រូវប្រកួតប្រជែងការងារនៅតាមរោងចក្រទាំងនេះ។ រោងចក្រចង់បានតែក្មេងស្រីណាដែលធ្លាប់មានបទពិសោធន៍ការងារពីមុន ហើយមានវិន័យធ្វើការបានច្រើនម៉ោងទៀងទាត់។ មជ្ឈមណ្ឌលស្តារលទ្ធភាពកុមារក្នុងព្រៃនប់មិនបានរៀនមេរៀនទាំងនេះក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈទេ។ អតិថិជនរៀនជំនាញដេរមូលដ្ឋាន ប៉ុន្តែមិនធ្លាប់បានប្រើម៉ាស៊ីនដូចដែលមានក្នុងរោងចក្រឡើយ។ អតិថិជនធ្វើការ ៤ម៉ោង ក្នុងមួយថ្ងៃ ហើយចំណាយពេលក្រៅពីនេះលើការអប់រំ និងការកំសាន្តផ្សេងៗ។ នេះមិនមែនជារបបដែលទទួលភារកិច្ចដ៏ធ្ងន់ធ្ងរដែលត្រូវគេ រំពឹងទុកពីស្ត្រីដែលធ្វើការរោងចក្រនោះឡើយ។

យើងនិយាយនៅទីនេះគឺ មិនស្តីបន្ទោសមជ្ឈមណ្ឌលនេះជាពិសេសនោះទេ។ មជ្ឈមណ្ឌលជាច្រើនផ្សេងទៀតបរាជ័យមិនបានធ្វើកិច្ចព្រមព្រៀងជាមួយរោងចក្របែបហ្នឹងផង។ ពោលគឺចង់និយាយថា ការបណ្តុះបណ្តាល

ជំនាញ និងវិន័យការងារមិនសមស្របទៅនឹងតំរូវទីផ្សារ។ នេះប្រហែលជាមិនបានយល់ស្របជាមួយនឹងតំរូវការដែលដាក់ក្មេងស្រីតាមរោងចក្រ ប៉ុន្តែវាជាភាពពិតនៃជីវិតសហសម័យនៅកម្ពុជា។ មានវិធីមួយទៀត គឺការសន្យាដើម្បីបង្កើតឱកាសការងារ ជាពិសេសសំរាប់អតិថិជនទាំងនេះ។ ឧទាហរណ៍ អង្គការ AFESIP ដំណើរការមជ្ឈមណ្ឌលនៅទីក្រុងភ្នំពេញ និងខេត្តសៀមរាប និងកំណត់គោលដៅលើក្មេងស្រីដែលត្រូវរំលោភបំពានជាពិសេស។ អង្គការក្រៅរដ្ឋាភិបាលបានចាប់ផ្តើមរោងចក្រកាត់ដេរផ្ទាល់ខ្លួនរបស់គេ។ វាហាក់ដូចជាចំលើយតបដ៏សមស្របទៅនឹងស្ថានភាពទីផ្សារដែលធ្វើឱ្យផលិតផលរបស់គេអាចមាននៅតាមទីផ្សារ។ យើងអាចសង្ឃឹមថា ការបណ្តុះបណ្តាលជំនាញដែលផ្តល់ឱ្យមជ្ឈមណ្ឌលស្របទៅនឹងតំរូវការរោងចក្រ ពីព្រោះវាជាកម្មសិទ្ធិរបស់អង្គការដូចគ្នា។ ទោះបីជាយើងមិនអាចទៅមើលដល់រោងចក្រ និងធ្វើការពិភាក្សាថា តើមជ្ឈមណ្ឌលផ្សេងទៀតអាចទាញប្រយោជន៍ពីការផ្តួចផ្តើមតាមវិធីណា ហើយធ្វើយ៉ាងដូចម្តេចចំណុចនេះយើងមានអារម្មណ៍ថាជាចំណុចមួយល្អ[២២]។ ចំនុចមួយទៀតគួរតែធ្វើផែនការអាជីពសំរាប់រាល់អតិថិជនឱ្យបានលឿនក្នុងកំឡុងពេលដែល ពួកគេកំពុងត្រូវបានស្តារលទ្ធភាពឡើងវិញ។ ផែនការអាជីពទាំងនេះផ្អែកលើទេពកោសល្យ ចំណង់ ជំនាញ និងបទពិសោធន៍ ដែលអតិថិជនមាន។ ផែនការនេះក៏ផ្អែកលើឱកាសការងារក្នុងតំបន់កន្លែង ដែលអតិថិជនត្រូវធ្វើសមាហរណកម្ម។ ដូច្នេះផែនការត្រូវបង្កើតឡើង និងទទួលយកវាបង្ហាញយ៉ាងច្បាស់នូវអ្វីជាតំរូវការអាជីពថ្មី។ មជ្ឈមណ្ឌលត្រូវផ្តល់ការបណ្តុះបណ្តាលលើជំនាញនេះ ឬបញ្ជូនអតិថិជនទៅកន្លែងណាទទួលបាននូវការបង្វឹកលើជំនាញទាំងនោះ។ មជ្ឈមណ្ឌលមួយចំនួនបានចាប់ផ្តើមនូវនិតិវិធីនេះ ហើយមានមណ្ឌលជាច្រើនធ្វើនាំគ្នាធ្វើតាម។ បន្ទាប់ពីការបណ្តុះបណ្តាលនៅពេលដែលអតិថិជនមានការងារ ភ្នាក់ងារដែលទទួលបន្ទុកលើដំណើរការសមាហរណកម្ម (អង្គការក្រៅរដ្ឋាភិបាលដែលផ្តល់ទីជម្រក ឬអាចជាអង្គការពិសេសណាមួយ) មិនត្រឹមតែធ្វើតាមដើម្បីត្រួតពិនិត្យលើដំណើរការរីកចំរើនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវគាំទ្រអតិថិជនអោយបានពេញលេញនូវការពិគ្រោះយោបល់ការងារ។ យើងត្រូវដឹងថា សំរាប់អតិថិជនភាគច្រើនដែលធ្វើការនៅក្នុងរោងចក្រ ហាង ឬសណ្ឋាគារ គឺជាបទពិសោធន៍ថ្មីសំរាប់ពួកគេ ហើយនិងអាចធ្វើអោយពួកគេភ័យខ្លាច។ អតិថិជនមិនទាន់បានទទួលចំណេះដឹងនូវអ្វីដែលគេគួរធ្វើ និងអ្វីដែលគេមិនគួរធ្វើដើម្បីរក្សាការងារឱ្យបានស្ថិតស្ថេរនោះ។ ពួកគេក៏មិនទាន់ទទួលបាននូវច្បាប់វិន័យនិងជាជំនាញដែលគេត្រូវការ

[២២] យើងចង់ទៅមើលមជ្ឈមណ្ឌល AFESIP និងរោងចក្រដើម្បីសិក្សាដោយផ្ទាល់អំពីបទពិសោធន៍នេះ ហើយសិក្សាផងដែរ អំពីសមត្ថភាពដទៃទៀតរបស់អង្គការក្រៅរដ្ឋាភិបាល។ ក្រុមបុគ្គលិកដែលមកពីមជ្ឈមណ្ឌលផ្សេងៗបានទៅមើលមជ្ឈមណ្ឌលភ្នំពេញក្នុងកម្មវិធីទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ឆ្នាំ ២០០២។ ពួកគេបានរាយការណ៍អំពីការអភិវឌ្ឍន៍ និងការប្រតិបត្តិដែលគួរអោយចាប់អារម្មណ៍ជាច្រើន។ ចំពោះហេតុផលនេះយើងមានគំរោងទៅមើលមជ្ឈមណ្ឌលភ្នំពេញ និងខេត្តសៀមរាប ក្នុងក្របខណ្ឌនៃការសិក្សាពីសមត្ថភាពបន្តរបស់យើងដើម្បីសិក្សាដោយផ្ទាល់អំពីការផ្តួចផ្តើមដែលគួរឱ្យចាប់អារម្មណ៍ទាំងនេះ។ ប៉ុន្តែអង្គការក្រៅរដ្ឋាភិបាលមិនបានលើកទឹកចិត្តការទៅមើលពីខាងក្រៅឡើយ ហើយជាទូទៅមិនបានធ្វើសហប្រតិបត្តិការជាមួយអង្គការផ្សេងៗ។ យើងនឹងព្យាយាមឱ្យមានអង្គការក្រៅរដ្ឋាភិបាលក្នុងការចុះស្រាវជ្រាវលើកក្រោយទៀត។

ដើម្បីផ្គាប់ចិត្តចៅហ្វាយគេនៅឡើយ។ ការពិគ្រោះយោបល់ការងារគឺជាផ្នែកមួយនៃដំណើរការសមាហរណកម្ម យ៉ាងហោចណាស់នៅក្នុងឆ្នាំដំបូង ដើម្បីគាំទ្រអតិថិជននិងដើម្បីដោះស្រាយបញ្ហាជាមួយនិយោជក។ បច្ចុប្បន្ននេះ យើងមិនទាន់បានដឹងពីកម្មវិធីពិគ្រោះយោបល់អាជីពនៅឡើយទេ។ នេះគឺ ជាលក្ខណៈពិសេសនៃជំនាញដែលអាច យកមកបង្ហាញនៅក្នុងប្រទេសយើងបាន[២៣]។

## ការបណ្តុះបណ្តាលសំរាប់អាជីវកម្ម

ការបង្កើតទីផ្សារសំរាប់ផលិតផលដែលបានធ្វើឡើងដោយក្រុមមនុស្សពិសេសគឺ ជាបញ្ហាចាស់ និងបញ្ហាទូទៅក្នុងប្រទេសកម្ពុជា។ អង្គការអភិវឌ្ឍន៍មួយចំនួនបានរកឃើញដំណោះស្រាយគួរអោយចាប់អារម្មណ៍ដើម្បីជ្រៀតចូលទីផ្សារ។ អង្គការក្រៅរដ្ឋាភិបាលហៅថា ដំណក់ទឹក Goutte D'Eau ដែលស្ថិតនៅប៉ោយប៉ែតផ្តល់ជម្រក និងការថែទាំក្មេងតាមចិញ្ចើមថ្នល់ឬកុមារអនាថា ក្នុងចំណោមក្មេងទាំងនោះ ក៏មានកុមារដែលត្រូវគេជួញដូរ និងរំលោភបំពានផងដែរ។ អង្គការនេះបានផ្តួចផ្តើមគំរោងពង្រីកប្រាក់ចំណូលក្នុងការបង្កើតរោងចក្រផលិតទឹកផឹក ដែលនៅទីនោះគាត់ដាក់អតិថិជនរបស់ខ្លួនធ្វើជាកូនជាង។ ក្មេងប្រុសដែលធ្វើការនៅក្នុងរោងចក្រ និងចែកចាយទឹកទៅអោយភូមិនៅក្បែរៗនោះ។ ប្រាក់ចំណូលដែលបានមកពីលក់ទឹកនោះ ត្រូវចំណាយលើប្រាក់ខែរបស់ពួកគេ។ គំរោងនេះគឺជាមធ្យោបាយដើម្បីអោយពួកគេមានលទ្ធភាពដោយខ្លួនឯង។ ឧទាហរណ៍ មួយផ្សេងទៀតនៃការផ្តួចផ្តើម ដែលឈរលើគោលការណ៍ទីផ្សារដែលអាចធ្វើអោយមាននិរន្តភាពនៅពេលមួយ គឺគំរោងសាកល្បងមកពីអង្គការក្រៅរដ្ឋាភិបាល ZOA Refugee Care នៅប៉ោយប៉ែតនៅតាមព្រំដែនប្រទេសថៃ។ ពួកគេបានរកឃើញថាសហគ្រិនតូចតាចនៅតាមមូលដ្ឋានកំពុងបណ្តុះបណ្តាលកម្មករដែលគេត្រូវការ។ មិនគ្រាន់ធ្វើកិច្ចការនេះបានត្រឹមត្រូវប៉ុណ្ណោះទេថែមទាំងវាមានតំលៃទាប និងមានរយៈពេលខ្លីទៀតផង។ ដើម្បីបង្កើតជំនាញការងារមិនតំរូវឱ្យមានអ្នកបង្វឹកមកពីខាងក្រៅ ឬរៀននៅតាមវិទ្យាស្ថានឡើយ[២៤]។ អ្នកផលិតសុទ្ធតែជាសហគ្រិនតូចតាចដែលធ្លាប់ជាអ្នកក្រីក្របំផុតរបស់សហគមន៍ខ្លួន។ គំរោងទាំងនេះបង្ហាញពីសក្តានុពលដែលអាចយកទៅអនុវត្តនៅកន្លែងផ្សេងៗទៀត។ មជ្ឈមណ្ឌលកុមារមួយ ចំនួនកំពុងព្យាយាមបង្កើតការងារផងដែរសំរាប់អតិថិជនរបស់ខ្លួន[២៥]។ អង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀតគួរប្រើវាជាគំរូពីរបៀប ដោះស្រាយបញ្ហានៃការខ្វះការងារធ្វើសំរាប់អតិថិជនខ្លួន។ មជ្ឈមណ្ឌលមួយចំនួនរួមបញ្ចូលជំនាញអាជីវកម្មទៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់គេ។ ប៉ុន្តែ

---

[២៣] COSECAM បានចាប់ផ្តើមជាមួយនឹងគំរោងដែលផ្តល់មូលនិធិដោយ USAID តាមរយៈ TAF ដើម្បីឆ្លើយតបពីពីតំរូវការបណ្តុះបណ្តាលវិជ្ជាជីវៈនៃការស្តារលទ្ធភាពកុមារ។ ការពិគ្រោះយោបល់ការងារត្រូវផ្តល់ជាផ្នែកមួយនៃសេវាកម្ម។

[២៤] ការថែទាំជនភៀសខ្លួន ZOA គំរោងប៉ោយប៉ែត ការស្រាវជ្រាវបង្ហាញនៅខែធ្នូ២០០៣ក្នុងទីក្រុងភ្នំពេញ

[២៥] បញ្ហាគឺការបង្កើតការងារថ្មី មិនមែនដាក់ជំនួសកម្មករជាមួយនឹងអតិថិជនឡើយ។ អង្គការវឌ្ឍនៈភាពក្នុងខេត្តពោធិសាត់ ជាភ្នាក់ងារគំរូមួយដោយផ្តោតលើការបង្កើតការងារសំរាប់អតិថិជនរបស់ខ្លួន។

យើងមិនអាចវាយតំលៃថាវាមានទំហំប៉ុនណាជាក់លាក់នោះទេនៃផ្នែកបណ្តុះបណ្តាល។ កម្មវិធីបណ្តុះបណ្តាលដែលយើងបានឃើញក្នុងពេលចុះមើលកម្រផ្តោតលើជំនាញអាជីវកម្មណាស់តែផ្តោតលើជំនាញវិជ្ជាជីវៈ។ លើសពីនេះទៀតសូម្បីតែនៅកន្លែងជំនាញអាជីវកម្មត្រូវបានលើកឡើង វានៅតែជាផ្នែកដ៏តូចមួយនៃការបណ្តុះបណ្តាល។ រឿងនេះវាមិនមានលក្ខណៈទូទៅចំពោះបទពិសោធន៍របស់អង្គការក្រៅរដ្ឋាភិបាល ដែលសិក្ខាកាមភាគច្រើនទទួលបរាជ័យក្នុងការបង្កើតអាជីវកម្មដែលមាននិរន្តរភាព។ ជាផ្នែកមួយនៃការវាយតំលៃកម្មវិធី យើងបានវាយតំលៃពីបុព្វហេតុដែលនាំឱ្យបរាជ័យ ឬជោគជ័យចំពោះអតិថិជនមួយចំនួនតូចដែលបានចាប់ផ្តើមអាជីវកម្ម[២៦]។ ទោះបីជាការវាយតំលៃនេះមិនបានស៊ីជម្រៅក៏ដោយ ក៏យើងបានរកឃើញកត្តាចំបង៧ប្រាំយ៉ាងចំពោះការបរាជ័យ។ ១- កង្វះខាតទេពកោសល្យ និងជំនាញសហគ្រិនគ្រឹន ២- ពុំមានផ្នែកបណ្តុញអាជីវកម្ម និងខ្វះការទំនាក់ទំនងអាជីវកម្ម ៣- តំរូវការទីផ្សារតិចតួចសំរាប់ផលិតផលដែលដាក់លក់ ៤- ភាពឃោឃៅនៃការប្រកួតប្រជែងចំពោះសហគ្រិនដែលល្អ ៥- ការចំណាយនៃប្រាក់កំចីវិនិយោគ និងបន្ទុក ការប្រាក់ខ្ពស់ពេក។

ហេតុដូច្នេះ វាបង្ហាញយ៉ាងច្បាស់ថាការបណ្តុះបណ្តាលជំនាញតែមួយមុខមិនជួយអតិថិជន ដែលចង់ចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនច្រើននោះឡើយ។ តំរូវការបឋមសំរាប់សហគ្រាសដែលជោគជ័យគឺតំរូវការសំរាប់ផលិតផល និងការចូលទៅក្នុងទីផ្សារ។ នេះជាកន្លែងដែលអតិថិជនជាច្រើនទទួលបរាជ័យ។ មុននឹងចាប់ផ្តើមបណ្តុះបណ្តាលជំនាញសំរាប់អតិថិជន មជ្ឈមណ្ឌលគួរតែដឹងអោយបានច្បាស់ថា មានតំរូវការសំរាប់ផលិតផល ហើយអាចដាក់លក់នៅទីផ្សារបានដែរឬទេ។ នៅពេលណាមានតំរូវការទាំងនេះ យើងអាចចុះឈ្មោះអោយអតិថិជនឱ្យចាប់ផ្តើមសិក្សាជំនាញ ក្នុងគោលបំណងចាប់ផ្តើមអាជីវកម្មដែលនឹងមានឱកាសទទួលជោគជ័យបាន។ យើងដឹងហើយថាមជ្ឈមណ្ឌលមួយចំនួនធ្វើការខិតខំវាយតំលៃពីស្ថានភាពទីផ្សារក្នុងតំបន់ដែលគេធ្វើការ។ យើងក៏ដឹងផងដែរថាមជ្ឈមណ្ឌលភាគច្រើនមិនមានសមត្ថភាពខិតខំប្រឹងប្រែងទាំងនេះអោយទទួលបានជោគជ័យនោះទេ - ការវាយតំលៃមិនមានការងាយស្រួលទេ ហើយតំរូវអោយមានជំនាញស្រាវជ្រាវទីផ្សារមួយចំនួនក្រៅពីផ្តល់ចំណេះដឹងពីស្ថានភាពអាជីវកម្មជាមូលដ្ឋាន។ យើងមិនបានដឹងថា នៅមានមជ្ឈមណ្ឌលណាខ្លះទេដែលខំប្រឹងប្រែងបែបហ្នឹងសំរាប់អតិថិជននោះ។ ប៉ុន្តែប្រសិនបើតំរូវទីផ្សារសំរាប់អតិថិជននោះត្រូវបានសំរេច គេមានឱកាសទទួលជោគជ័យបាន។

នៅពេលអតិថិជនបានរៀនវគ្គបណ្តុះបណ្តាលចប់ហើយ នាងត្រូវការហិរញ្ញវត្ថុដើម្បីចាប់ផ្តើមអាជីវកម្មរបស់នាង។ ប្រសិនបើនេះស្ថិតនៅក្នុងទំរង់នៃប្រាក់កំចី បន្ទុកប្រាក់កំចីនោះមិនគួរធ្វើអោយនាំទៅរកភាពបរាជ័យ

[២៦] ការវាយតំលៃទាំងនេះត្រូវធ្វើឡើងក្នុងចំណោមអតិថិជនរបស់អង្គការក្រៅរដ្ឋាភិបាលដោយទទួលប្រាក់សំរាប់ស្រាវជ្រាវពី SKN ដោយអ្នកស្រាវជ្រាវ ECR កម្ពុជា

នោះទេ។ មជ្ឈមណ្ឌល ឬភ្នាក់ងារផ្តល់ប្រាក់កំចីត្រូវដឹងថានៅពេលខ្លះអាជីវកម្មនឹងមិនទទួលប្រាក់ចំណេញសំរាប់សងវិញទេ ជាពិសេសនៅឆ្នាំដំបូង។ ការតំរូវអោយបង់ប្រាក់ដើម និងការប្រាក់ក្នុងដំណាក់កាលចាប់ផ្តើមនេះធ្វើអោយខូចប្រយោជន៍ដែលនាំទៅរកភាពជោគជ័យនៃអាជីវកម្ម។ លើសពីនេះទៀត អតិថិជនដែលចាប់ផ្តើមអាជីវកម្មថ្មីត្រូវការការគាំទ្រដើម្បីស្ថាបនាទំនាក់ទំនងអាជីវកម្មរបស់នាង។ ដោយគ្មានការទំនាក់ទំនងបែបនេះ អាជីវកម្មជាទូទៅមិនទទួលជោគជ័យឡើយ។ កត្តាទាំងអស់នេះ គួរលើកយកមកពិភាក្សាហើយធ្វើផែនការអាជីវកម្មដែលផ្តល់ឱ្យនូវឱកាសសមស្រប ដែលនាំអោយមានភាពជោគជ័យមុននឹងអោយអតិថិជនដែលចង់បើកអាជីវកម្មវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។ រឿងបែបនេះ យើងមិនបានឃើញមានការប្រតិបត្តិណាមួយក្នុងចំណោមមជ្ឈមណ្ឌលដែលបានទៅមើលនោះឡើយ។ យើងមានការសង្ស័យថា តើមានការប្រតិបត្តិនៅមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារដទៃទៀតដែរឬទេ។

## សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ

អង្គការក្រៅរដ្ឋាភិបាលមួយចំនួនផ្តល់ជាអាហារលើការបណ្តុះបណ្តាលវិជ្ជាជីវៈនេះ ដែលជាតំរូវការរបស់អតិថិជន និងក្មេងស្រី ឬស្ត្រីក្មេងៗដែលសង្ឃឹមថាមានជំនាញល្អដែលពួកគេនឹងមានការងារ ឬទទួលជោគជ័យលើអាជីវកម្មខ្នាតតូច។ ដូចយើងបានលើកឡើងខាងលើនេះ គឺសាលាវិជ្ជាជីវៈរបស់ HCC ក្នុងខេត្តព្រៃវែង និងសាលាដែលទើបផ្តួចផ្តើមថ្មីនៅជិតទីក្រុងភ្នំពេញ។ មូលនិធិដុនបូស្កូ បានបង្កើតសាលាបច្ចេកទេសនៅក្នុងទីក្រុងជាច្រើនដែលសាលាចុងក្រោយគេបង្អស់នៅប៉ោយប៉ែត។ ពួកគេមានបំណងចុះឈ្មោះកុមារ (ប្រុសនិងស្រី)ដែលត្រូវគេជួញដូរ គ្មានផ្ទះសម្បែង ឬទទួលរងនូវរឿងរ៉ាវផ្សេងៗ។ មជ្ឈមណ្ឌលនៅព្រៃនប់ក្រុងព្រះសីហនុដែលបានលើកឡើងខាងលើក៏បើកសាលាបណ្តុះបណ្តាលកាត់ដេរផងដែរសំរាប់ក្មេងស្រីដែលមកពីគ្រួសារក្រីក្រ។ យើងបានដឹងថា មានអង្គការផ្សេងៗទៀតដែលផ្តល់ការបណ្តុះបណ្តាលជំនាញដល់ក្មេងៗ ឧទាហរណ៍ អង្គការ CSARO សំរាប់កុមាររើសសំរាម។ ប៉ុន្តែយើងមិនបានដឹងមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារដទៃទៀត ដែលផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងសាលាដែលមិនបានកំណត់អតិថិជននោះទេ។ ចំពោះជំនាញប្រតិបត្តិដែលជាតម្រូវការ និងធនធានការប្រតិបត្តិរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពកុមារមានកំណែទំរង់ថ្មីផ្ទាល់ខ្លួននៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សំរាប់អតិថិជនរបស់ខ្លួននោះ គឺពុំទាន់មានប្រសិទ្ធិភាពគ្រប់គ្រាន់ពោលគឺត្រូវចូលរួមជាមួយគ្នាទើបប្រសើរ។ បច្ចុប្បន្ននេះ អង្គការជាច្រើនមានការស្ទាក់ស្ទើរមិនព្រមបោះបង់នូវការប្រតិបត្តិដែលគេបង្កើតឡើង ហើយបោះបង់ "តំបន់" របស់ខ្លួន។ អង្គការក្រៅរដ្ឋាភិបាលត្រូវការបញ្ចុះបញ្ចូលខ្លួនឯង ដែលត្រូវតែបំរើផលប្រយោជន៍របស់អតិថជនរបស់ខ្លួន នឹងរួមគ្នាធ្វើការងារនេះ។ ក្នុងចំណោម "ការប្រតិបត្តិដ៏ប្រសើបំផុត" មកពីផ្នែកផ្សេងៗនៃពិភពលោកដែលអាចផ្តល់ដំណោះស្រាយចំពោះបញ្ហាដែលនិយោជកផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈគឺ ការបង្កើតសាលាបណ្តុះបណ្តាលពិសេស។ សាលានេះត្រូវជ្រើសរើសគ្រូដែលមានជំនាញ និងពិសោធន៍ផ្សេងៗ ហើយចេះបទបែនទៅតាម

តំរូវការឧស្សាហកម្មថ្មីៗ។ សាលានេះក៏អាចរៀបចំផងដែរឱ្យមាននិយោជកប្រកបដោយទស្សនវិស័យដែលអាចឱ្យនិស្សិតនឹងទទួលបាននូវបទពិសោធន៍ជាក្តូនជាងក្នុងការបណ្តុះបណ្តាលជំនាញបន្ត។ ធ្វើបែបនេះនឹងបង្កើននូវការផ្លាស់ប្តូរដើម្បីទទួលបាននូវការងារ បន្ទាប់ពីការបណ្តុះបណ្តាលបានបញ្ចប់។ ប៉ុន្តែនេះគឺជាដំណោះស្រាយសំរាប់តំបន់ទីក្រុងដែលមានអតិថិជនគ្រប់គ្រាន់មកចុះឈ្មោះ ក្នុងកម្មវិធីបណ្តុះបណ្តាល។ វាមិនមែនជាដំណោះស្រាយសំរាប់អតិថជន ដែលរស់ក្នុងមជ្ឈមណ្ឌលនៅជនបទឡើយ។ត្រូវមានវិធានការពិសេសដូចជា បញ្ជូនអោយអតិថិជនទៅកាន់កន្លែងដែលជំនាញវិជ្ជាជីវៈដែលគេចង់រៀន។ យើងស្នើអោយស្វែងរកនូវជម្រើសនៃការបង្កើតក្នុងមជ្ឈមណ្ឌលក្នុងក្រុងនីមួយៗនូវសាលាវិជ្ជាជីវៈ ឬប្រសិនបើមានសាលាដែលស្រដៀងគ្នា ដោយស្វែងរកនូវលទ្ធភាពដែលអាចបទបែនទៅតាមប្រព័ន្ធសំរាប់អតិថិជននៅមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារ។ សាលាវិជ្ជាជីវៈត្រូវមានការចូលរួមពីមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារមួយចំនួន ហើយត្រូវផ្តល់វគ្គបណ្តុះបណ្តាលមួយចំនួនទៀត។ វគ្គនេះត្រូវតែរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយនឹងអនាគតនិយោជក។ អតិថិជនមកពីមជ្ឈមណ្ឌលដែលស្ថិតក្នុងតំបន់ទីក្រុងអាចស្នាក់ក្នុងមជ្ឈមណ្ឌលរបស់ខ្លួន ប៉ុន្តែត្រូវចូលរៀននៅពេលថ្ងៃ។ ក្នុងករណីដែលអតិថិជនចង់រៀនជំនាញដែលជំនាញនោះមិនមាននៅទីក្រុងជាកន្លែងដែលពួកគេរស់នៅ ប៉ុន្តែមានតំបន់ផ្សេងទៀតមជ្ឈមណ្ឌលស្តារលទ្ធភាពត្រូវធ្វើការរៀបចំបញ្ជូនអតិថិជននោះទៅកាន់មជ្ឈមណ្ឌលណាមួយនៅកន្លែងនោះ។ ផលប្រយោជន៍តំរូវការ និងសេចក្តីត្រូវការរបស់អតិថិជន គឺត្រូវស្វែងរកទីជម្រករស់នៅជាមូលដ្ឋាន គឺមិនចាំបាច់តែមណ្ឌលធ្វើការ "ជួយសង្គ្រោះ" កុមារមួយមុខប៉ុណ្ណោះនោះទេ។

## សេចក្តីត្រូវការសំរាប់ការថែទាំក្នុងមណ្ឌល

នៅក្នុងរបាយការណ៍នេះយើងផ្តោតទៅលើមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារ ហេតុដូច្នេះមិនផ្តោតលើមណ្ឌលដែលថែទាំកុមាររយៈពេលយូរ ឬការផ្តល់ការស្នាក់នៅដល់មនុស្សពេញវ័យនោះឡើយ។ ការពិភាក្សាអំពីសេចក្តីត្រូវការសំរាប់មជ្ឈមណ្ឌលភាគច្រើន ដូច្នេះមិនកំណត់មជ្ឈមណ្ឌលដែលផ្តល់ជម្រក និងថែទាំដល់កុមារដែលត្រូវរំលោភបំពាន ឬមិនត្រូវគេអើពើ (មើលប្រភេទកុមារដែលបានកំណត់នៅទំព័រទី១)។ របាយការណ៍ស្តីអំពីមណ្ឌលផ្តល់ជម្រកដែលរៀបចំឡើងដោយអង្គការអាដហុកថ្លែងថា *"វាជាការពិតដែលថាពុំមាន ជម្រកអោយបានគ្រប់គ្រាន់អោយត្រូវទៅតាមសេចក្តីត្រូវការ"*[២៧] ។ នៅក្នុងសេចក្តីផ្តើមនៃរបាយការណ៍និយាយថា គោលបំណងគឺ ត្រូវត្រួតពិនិត្យស្ថានភាពនៅតាមមណ្ឌលដែលទទួលជនរងគ្រោះដោយអំពើហឹង្សារក្នុងគ្រួសារ ការរំលោភ និងការជួញដូរ (ទំព័រ២)។ ហេតុដូច្នេះយើងសន្និដ្ឋានថាមានសេចក្តីត្រូវការសំរាប់ទីជម្រកចំពោះក្រុមទាំងនេះ។ បញ្ជីសារពើភ័ណ្ឌរបស់មជ្ឈមណ្ឌលជាមួយនឹងក្រុមគោលដៅរួមទាំងប្រភេទទាំងបីដូចបានលើកឡើងខាងលើដែលបានធ្វើឡើង

[២៧] របាយការណ៍ពង្រាងស្តីពីជម្រកក្នុងតំបន់ក្រុងភ្នំពេញ អង្គការអាដហុកផ្នែកស្ត្រី ខែកញ្ញា ២០០៣ ទំព័រ៤

ក្នុងឆ្នាំ ២០០៣ បានរកឃើញអង្គការចំនួន ១២ ដែលភាគច្រើនមានសមត្ថភាពអោយម្ហូបអាហារបរិភោគសំរាប់មនុស្សប្រហែល៣០នាក់[២៨] ប៉ុណ្ណោះ។ នៅក្នុងមជ្ឈមណ្ឌលមួយចំនួនអតិថិជនស្នាក់នៅរយៈពេលតិចជាង ៦ខែ ខ្លះទៀតអាចស្នាក់នៅបានរហូតដល់ជាងពីរឆ្នាំជាគោលនយោបាយ[២៩]។ ប៉ុន្តែអតិថិជន អាចស្នាក់នៅជាអប្បបរមាកន្លះឆ្នាំ[៣០]។ វាអាចនិយាយបានថាចំនួនអ្នកស្នាក់នៅក្នុងមជ្ឈមណ្ឌលប្រចាំឆ្នាំ គឺកើនឡើងពីរដងទៅនឹងចំនួនដែលត្រូវបានរកឃើញ។ ដូច្នេះមានយ៉ាងហោចណាស់លទ្ធភាពដែលអាចផ្តល់អាហារសំរាប់អតិថិជន ១២ x ៣០ x ២ =៧២០នាក់ ក្នុងមួយឆ្នាំៗ។ លើសពីនេះទៀត មានមជ្ឈមណ្ឌលមួយចំនួនដែលមិនបានរាប់បញ្ចូលពីការកើនឡើងនូវលទ្ធភាពដែលផ្តល់អាហារក្នុងប្រទេសបាន។ យើងទស្សទាយនូវលទ្ធភាពផ្តល់អាហារសំរាប់ការរស់រានសំរាប់កុមារដែលគេរំលោភបំពានដែលមានពី ៧៥០ ទៅ ៨៥០នាក់ ក្នុងមួយឆ្នាំ។ សារពើពន្ធដែលគួរអោយជឿជាក់បានថ្មីៗនេះអំពីចំនួនពេស្យាចារជាក់ស្តែងក្នុងប្រទេសមានប្រមាណ ២០០០នាក់ ដែលជាអ្នករកស៊ីបំរើផ្លូវភេទក្រោមអាយុ ១៨ឆ្នាំ។ ចំនួនដ៏ច្រើននៃពេស្យាចារក្រោមអាយុទាំងនេះ កំពុងធ្វើការដោះបំណុលហើយភាគច្រើនមិនបានចាប់អារម្មណ៍នឹងការស្នាក់នៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាព ឬរៀនការងារផ្សេងទៀតឡើយ ប្រសិនបើពួកគេពុំមានលុយដោះបំណុលទេ[៣១]។ យោងទៅតាមរបាយការណ៍មានអ្នករកស៊ីបំរើផ្លូវភេទប្រហែល ៣០% ដែលមិនចាប់អារម្មណ៍ពីការ "ជួយសង្គ្រោះ"។ ដូច្នេះ កុមារ៧០% នៃចំនួនប្រហែលជា២០០០នាក់ ឬ ១៤០០នាក់ ត្រូវគេបង្ខំឱ្យចូលក្នុងសកម្មភាពពាណិជ្ជកម្មផ្លូវភេទ ហើយប្រហែលភាគច្រើនមានបំណងចេញពីស្ថានភាពកេងប្រវ័ញ្ចនេះ។ បច្ចុប្បន្ននេះ យើងអាចមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងប្រទេសយើដើម្បីជួយក្រុមនេះបានពាក់កណ្តាល។ ប៉ុន្តែការខិតខំជួយសង្គ្រោះគឺ កម្រនឹងទទួលជោគជ័យណាស់។ ដូច្នេះជាទូទៅមានពេស្យាចារកុមារតិចជាង ៥០% ក្នុងមួយឆ្នាំៗដែលត្រូវបានគេជួយសង្គ្រោះ។ តាមពិតវាហាក់ដូចជាមានសមាមាត្រទាបជាងមុន។ ទោះបីជាការប៉ាន់ស្មានត្រឹមត្រូវមួយនៃប្រភេទកុមារ និងស្ត្រីដែលត្រូវគេរំលោភបំពាន ឬមិនអើពើមិនអាចធ្វើឡើងដោយគ្មានទិន្នន័យពីមជ្ឈមណ្ឌលទាំងអស់នេះទេក៏ដោយ ក៏យើងមានវិធីមួយទៀតដើម្បីបង្កើតប្រព័ន្ធក្នុងការប្រមូលពតិមានប្រសិនបើមានសេចក្តីត្រូវការពិតប្រាកដពីមជ្ឈមណ្ឌលច្រើនទៀតនោះ។ អង្គការ AFESIP ត្រូវគេរាយការណ៍មកថា មានក្មេងស្រី និងស្ត្រីក្មេងៗជាង ២០០នាក់ នៅមជ្ឈមណ្ឌលភ្នំពេញរបស់ខ្លួន ហើយនេះត្រូវបានពង្រីកលទ្ធភាពរបស់ខ្លួនកាន់តែធំ[៣២]។ សំរាប់អង្គការ CWCC ត្រូវគេរាយការណ៍ផងដែរថា ជាញឹកញាប់មានអតិថិជន

---

[២៨] លក់ដូចដូចសត្វមាន់ ២០០៣ COSECAM របាយការណ៍ នរ.០០៦ ឧបសម្ព័ន្ធ A

[២៩] ឧទាហរណ៍ បុគ្គលិកមកពីផ្ទះនៃក្តីសង្ឃឹមបានផ្តល់ព័ត៌មានឱ្យពួកយើងថា វាជាគោលនយោបាយរបស់ខ្លួនដើម្បីផ្តល់អាហារឱ្យអតិថិជនរយៈពេលយ៉ាងហោច ២ឆ្នាំ។

[៣០] ដេតាបេសមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារ COSECAM

[៣១] ការវាស់វែង...Steinfath, UNDP ២០០៣

[៣២] របាយការណ៍ពង្រាងស្តីពីជម្រកក្នុងតំបន់ភ្នំពេញ អង្គការអាដហុកផ្នែកស្ត្រី កញ្ញា២០០៣ ទំព័រ៦

លើសពីលទ្ធភាពរបស់ខ្លួន[៣៣] ។ មជ្ឈមណ្ឌលទាំងពីរនេះមិនបានរាយការណ៍ពីអតិថិជនដែលមិនត្រូវគេរំលោភបំពាន ឬមិនអើពើឡើយ ។ ប៉ុន្តែមជ្ឈមណ្ឌលផ្សេងភាគច្រើនមានសមាមាត្រអតិថិជនខ្ពស់ដែលជាញាតិសន្តានដែលមិនមែនជាប្រភេទដែលត្រូវគេរំលោភបំពាន ឬមិនអើពើឡើយ ។ របាយការណ៍សំរាប់ម្ចាស់ជំនួយចង្អុលបង្ហាញថា មានប្រជាជនជាង១/៣នៃមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារមានអតិថិជនដែលគ្មានជំនាញ ហើយដែលត្រូវការការបណ្តុះបណ្តាល វិជ្ជាជីវៈ[៣៤] ។ មជ្ឈមណ្ឌលប្រហែល ១០ បានប្រើលទ្ធភាពរបស់ខ្លួនមិនដល់ ៥០% ផងក្នុងមួយឆ្នាំស្មើនឹងអតិថិជនប្រហែល៣០០នាក់ ។ ដូច្នេះវាហាក់ដូចជា អង្គការ AFESIP និង CWCC ទទួលចំនួនលើសកំណត់ដែលអាចគ្របដណ្តប់ចំនួនកុមារ ដែលមជ្ឈមណ្ឌលស្តារលទ្ធភាពដ៏ទៃទៀតមិនបានទទួល ។ បញ្ហានេះហាក់ដូចជាមានការបែងចែកអតិថិជនសមស្របទៅលើមជ្ឈមណ្ឌលដែលមានស្រាប់ ។ ជំនួសនៃការបង្កើតឱ្យមានមជ្ឈមណ្ឌលច្រើន យើងត្រូវតែបញ្ជូនអតិថិជនទៅមណ្ឌលណាដែលអាចមានសមត្ថភាពទទួលយកពួកគេបាន ។ យើងដឹងថាការអះអាងនឹងត្រូវបានលើកឡើងថា មជ្ឈមណ្ឌលមូនចំនួនមិនបានផ្តល់នូវការថែទាំ និងបំរើសេវាអោយបានសមរម្យ ។ តាមពិតប្រសិនបើគុណភាពនៃការថែទាំសេវាកម្មគឺ ជាបញ្ហាជំនួសនៃការបង្កើតមជ្ឈមណ្ឌលបន្ថែម យើងទាំងអស់គ្នាគួតែខិតខំកែលំអគុណភាពនៃការថែទាំ និងការផ្តល់សេវាក្នុងមជ្ឈមណ្ឌលដែលមានស្រាប់ ។ ប្រទេសជាតិ និងជនរងគ្រោះដោយសាការរំលោភបំពាន មិនគួរត្រូវបានផ្តល់សេវាដោយមជ្ឈមណ្ឌលភាគច្រើនដែលប្រើប្រាស់នូវធនធានដែលត្រូវការឡើយ ។ ដើម្បីចៀសវាងការយល់ច្រឡំ យើងនឹងធ្វើការពិភាក្សាអំពីមជ្ឈមណ្ឌលស្តារលទ្ធភាពសំរាប់កុមាររកស៊ីផ្លូវភេទ ឬកុមារដែលទទួលរងនូវការរំលោភបំពានផ្សេងៗ ។ ប្រហែលជាមានតំរូវការសំរាប់ប្រភេទនៃការថែទាំតាមស្ថាប័នផ្សេងទៀត ឬសំរាប់ជនរងគ្រោះប្រភេទផ្សេងទៀត ឧទាហរណ៍ កុមារកំព្រាដែលឪពុកម្តាយស្លាប់ចោលដោយសារជម្ងឺអេដស៍ ហើយពួកគេត្រូវបានគេបដិសេធដោយសំណាញ់សុវត្ថិភាពប្រពៃណីសំរាប់កុមារកំព្រា ។

## ការបញ្ជូនអតិថិជន

ដូចបានរៀបរាប់មកខាងដើមថា អង្គការដែលល្បីៗមានការស្ទាក់ស្ទើរបញ្ជូនអតិថិជនទៅមជ្ឈមណ្ឌលផ្សេងទៀត ។ តាមពិតបញ្ហាបញ្ជូនតែងតែកើតមានជាញឹកញាប់ ឬជាធម្មតាទៅហើយ ។ បញ្ហាចុងក្រោយនេះគឺស្ថិតនៅក្រោមការពិភាក្សា ហើយមិនងាយស្រួលដោះស្រាយឡើយ ។ តើវាជាការរំលោភសិទ្ធិកុមារដែរឬទេ ប្រសិនបើពួកគេត្រូវបានហាមឃាត់មិនអោយជួបញាតិសន្តានរបស់គេ ឬទុកតែក្នុងរបងនៅពេលដែលភ្នាក់ងារមានការភ័យខ្លាចថាអតិថិជនត្រូវគេធ្វើបាប? អង្គការអាដហុកបានសំរេចចិត្តថាវាស្ថិតនៅក្នុងអាណត្តិរបស់ខ្លួន ដើម្បី

[៣៣] ការទំនាក់ទំនងផ្ទាល់

[៣៤] របាយការណ៍សម្ងាត់ទៅអោយ SKN ប្រហែល៦មជ្ឈមណ្ឌល

ត្រួតពិនិត្យពីស្ថានភាពកុមារនៅតាមជម្រកដើម្បីអោយច្បាស់ថាសិទ្ធិកុមារមិនត្រូវគេរំលោភ។ ជាអកុសលមណ្ឌលមួយក្នុងចំណោមមជ្ឈមណ្ឌលទាំងនោះមិនបានយល់ស្របថា វាជាអាណត្តិរបស់អង្គការអាដហុកទេ ដែលត្រួតពិនិត្យមជ្ឈមណ្ឌលរបស់ពួកគេនោះ[៣៥] ។ ទោះបីជាយើងបញ្ចេញជាយោបល់ថា រាល់ភ្នាក់ងារតាមដានសិទ្ធិមនុស្សមានអាណត្តិដើម្បីស៊ើបអង្កេតពីការរំលោភសិទ្ធកុមារ ដោយមិនគិតពីភ្នាក់ងាររដ្ឋាភិបាល ឬឯកជនឡើយ បញ្ហាចំបងនៅទីនេះគឺអាណត្តិរបស់ខ្លួន តើវាត្រូវសំរេចថាតើជនរងគ្រោះមកពីណាហើយត្រូវទៅកន្លែងណា និងត្រូវផ្តល់អោយនៅក្រោមលក្ខខណ្ឌថែរក្សាបែបណា?

យើងបានជួបក្រុមមនុស្សដែលពាក់ព័ន្ធនៅក្នុងរដូវក្តៅនាឆ្នាំ២០០២ ដើម្បីធ្វើការពិភាក្សាលើបញ្ហានេះ។ ការផ្តើមកិច្ចពិភាក្សនេះ ត្រូវធ្វើឡើងដោយក្រុមមួយទៀតក្នុងរដូវស្លឹកឈើជ្រុះឆ្នាំ ២០០២ ហើយនាំទៅរកទស្សនាទាន នៃ "ដើម្បីបង្កើតមណ្ឌលសំចត"[៣៦] ។ មានការយល់ឃើញថា ភ្នាក់ងារពាក់កណ្តាលរដ្ឋាភិបាល SKK ជាផ្នែកមួយ របស់ក្រសួងសង្គមកិច្ចជាអ្នកទទួលខុសត្រូវលើការបញ្ជូនកុមារ រងគ្រោះដោយសារការរំលោភបំពានទៅមជ្ឈមណ្ឌល ស្តារលទ្ធភាពឬ ទៅកន្លែងថែទាំជំនួសផ្សេងទៀត។ ទោះបីជាភ្នាក់ងារមានដំណើរការនិងអង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងភ្នាក់ងារក្រសួងដែលពាក់ព័ន្ធសុំអោយមានការចូលរួមក្នុងការដោះស្រាយបញ្ហានេះ យ៉ាងណាក៏ដោយ ក៏គ្រប់ៗគ្រប់គ្នាមិនព្រមសហប្រតិបត្តិការមិនបាន សហការក្នុងការងារនេះដែរ។ វាប្រហែលជាដល់ ពេលដែលត្រូវបង្កើតច្បាប់ និងការសហការគ្នាហើយ។ តាមពិតវិធានការនេះត្រូវតែធ្វើឡើងដោយប្រុងប្រយត្ន័ ហើយគ្រប់អង្គការដែលពាក់ព័ន្ធទាំងអស់ត្រូវធ្វើការពិគ្រោះយោបល់អំពីច្បាប់និងផលវិបាកសំរាប់ភ្នាក់ងារខ្លួន។ ការឈានដល់កិច្ចព្រមព្រៀងលើបញ្ហានេះពិតជាប្រសើរ ជាងការបង្ខំអោយអនុវត្តច្បាប់ ប៉ុន្តែនៅទីបញ្ចប់ សុខមាលភាពរបស់អតិថិជនត្រូវតែជាអាទិភាពដែលយើងគួរគិតដល់។

ការសំរេចចិត្តលើស្ថានភាពថែទាំ និងលើសេវាសំរាប់អតិថិជនគឺ ជាការចាំបាច់មិនគ្រាន់តែជាបញ្ហាអនុវត្តឬជាគោលការណ៍ប៉ុណ្ណោះទេ តែជាបញ្ហាច្បាប់។ ប្រទេសកម្ពុជាជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យហើយអង្គការសង្គមស៊ីវិលដូចជាប្រជាពលរដ្ឋគួរតែគោរពច្បាប់។ នៅក្នុងប្រទេសលទ្ធិប្រជាធិបតេយ្យច្បាប់ចេញមកពីការព្រមព្រៀងជាទូទៅ ហើយលទ្ធផលនៃការព្រមព្រៀងនេះបានមកពីអ្វីដែលជាការសំរេចចិត្តសំលេងភាគច្រើន។ ច្បាប់សំរាប់លក្ខខណ្ឌស្ថិតនៅក្រោមមជ្ឈមណ្ឌលស្តារលទ្ធភាព (កុមារ) ដូចនេះអ្នកថែទាំអតិថិជន គួរតែអភិវឌ្ឍតាមរយៈដំណើរការមតិទូទៅ។ អង្គសិក្ខាសាលាពីរស្តីពី ការថែទាំនៅតាមមណ្ឌល (មីនា និងតុលា២០០៣) និង

---

[៣៥] របាយការណ៍ពង្រាងស្តីពីជម្រកក្នុងតំបន់ក្រុងភ្នំពេញ អង្គការអាដហុកផ្នែកស្ត្រី កញ្ញា២០០៣ ទំព័រ៦និង៧

[៣៦] ការពិភាក្សាដំបូងត្រូវផ្តួចផ្តើមឡើងដោយអង្គការ UNICEF និងអង្គការផ្សេងៗក្នុងរដូវក្តៅ២០០២។ វគ្គពិភាក្សាលើកទីពីរត្រូវបានរៀបចំដោយ COSECAM ចុងឆ្នាំ២០០២ និងដើមឆ្នាំ ២០០៣។ បញ្ហានេះត្រូវបានពិភាក្សាម្តងទៀត នៅអង្គសិក្ខាសាលាថ្នាក់ជាតិនៅថ្ងៃទី១៧ ខែមីនាឆ្នាំ ២០០៣ (របាយការណ៍លេខ៥ COSECAM)

គណៈកម្មការពង្រាងក្របខណ្ឌច្បាប់ដោយផ្អែកលើលទ្ធផលនៃអង្គសិក្ខាសាលាទាំងនេះ បានកំណត់និន្នាការសំរាប់ដំណើរការនេះ[៣៧] ។ នេះជាដំណើរការលទ្ធិប្រជាធិបតេយ្យ និងអង្គការសង្គមស៊ីវិលមិនថាគេយល់ស្រប ឬមិនយល់ស្របឡើយ គួរតែគោរពទៅតាមអ្វីដែលជាសំលេងភាគច្រើនដែលបានសំរេចឡើង។ វាគឺជា "ច្បាប់" ដែលកុមារត្រូវបានជួយសង្គ្រោះពីស្ថានភាពរំលោភបំពានត្រូវបញ្ជូនតាមរយៈភ្នាក់ងាររបស់ក្រសួងសង្គមកិច្ច ហៅថា សេវាការពារកុមា "SKK" ហើយសេវាការពារកុមាបញ្ជូនបន្តទៅអោយមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារដែលសមស្របបំផុតប្រសិនបើដំណោះស្រាយមួយទៀតមិនអាចធ្វើទៅបាន ឧទាហរណ៍ ញាតិសន្តាន ឬគ្រួសារចិញ្ចឹម។

## ផលប៉ះពាល់នៃការសង្គ្រោះ

សេចក្តីត្រូវការរបស់មជ្ឈមណ្ឌលមិនដូចទៅនឹងតំរូវការស្ថាប័នឡើយ។ ទីមួយគឺយើងអាចក្រឡេកមើលលើការថែទាំជំនួសផ្សេងៗ ដូចជាការថែទាំនៅតាមមណ្ឌល ដូចជាឪពុកម្តាយចិញ្ចឹម ម្យ៉ាងមិញទៀតយើងក្រឡេកមើលផងដែរនូវផលប៉ះពាល់នៃការសង្គ្រោះជនរងគ្រោះ។ បញ្ហានៃការថែទាំក្រៅមណ្ឌល គឺនៅឆ្ងាយពីវិសាលភាពនៃអត្ថបទនេះ។ ដំណោះស្រាយក្នុងការដាក់កុមារនៅតាមស្ថាប័នឬមណ្ឌលត្រូវតែជាដំណោះស្រាយចុងក្រោយបានន័យថា ការថែទាំជំនួសនៅតាមបែបសហគមន៍វាត្រូវតែជាអត្តិភាពសំរាប់កុមាដែលជាជនរងគ្រោះ។ ប៉ុន្តែយើងត្រូវនិយាយអំពីផលប៉ះពាល់នៃការជួយសង្គ្រោះជនរងគ្រោះពីការកេងប្រវ័ញ្ច "ពីការធ្វើអាជីវកម្ម" និងកុមារផ្សេងៗទៀត។

*មានពេស្យាចារកុមារពីរប្រភេទគឺ អ្នកដែលចេះអាន-សរសេរត្រូវគេបង្ខំអោយធ្វើការជាអ្នកបម្រើផ្លូវភេទ និងអ្នកដែលត្រូវគេបង្ខំអោយធ្វើជាពេស្យាចារ។ គ្មានកុមារណាមួយលក់ខ្លួនដោយស្ម័គ្រចិត្តនោះឡើយ[៣៨] ។ ក្រុមទីពីរនេះជាកុមារដែលឪពុក-ម្តាយរបស់គេត្រូវបង់ដោះបំណុល ហើយអោយកូនស្រីធ្វើការដើម្បីរកប្រាក់តាមរយៈបំរើផ្លូវភេទ។ នេះគឺជាស្ថានភាពទូទៅមួយក្នុងចំណោមពេស្យាចារកុមារដែលមកពីប្រទេសវៀតណាម[៣៩] ។ ពុំមាន*

[៣៧] សិក្ខាសាលាស្តីពីស្តង់ដារអប្បបរមា និងការគ្រប់គ្រងមជ្ឈមណ្ឌល ១៧ មីនា ២០០៣ (របាយការណ៍០០៦ COSECAM) និងអង្គសិក្ខាសាលាស្តីពីការថែទាំនៅតាមមណ្ឌលខែតុលា ២០០៣ (រៀបចំឡើងដោយក្រសួងសង្គមកិច្ច) គណៈកម្មាធិការក្របខណ្ឌច្បាប់មានអ្នកតំណាងរបស់ក្រសួងសង្គមកិច្ច និងក្រសួងយុត្តិធម៌, អង្គការ UNICEF, IOM, COSECAM, ក្រុមសុខមាលភាពកុមារ និងអង្គការផ្សេងៗ។

[៣៨] នេះអាចជាករណីក្នុងប្រទេសផ្សេងទៀត ដូចជានៅជប៉ុនសិស្សវិទ្យាល័យទៅធ្វើពេស្យាចារដោយខ្លួនឯង ដើម្បីយកលុយដាក់ហោប៉ៅ ឬនិស្សិតសាកលវិទ្យាល័យនៅប្រទេសថៃលក់ខ្លួនដើម្បីបង់ថ្លៃរៀន ប៉ុន្តែរឿងនេះមិនទាន់លេចឮនៅប្រទេសកម្ពុជានៅឡើយទេ។ ស្លាកស្នាមទុរយសនៃ "ស្ត្រីខូចចិត្តរារាំងមិនឱ្យក្មេងស្រីធ្វើជាពេស្យាចា" ដោយស្ម័គ្រចិត្ត។ ប្រសិនបើគេជ្រើសយក គឺដោយសារគេបាត់បង់ព្រហ្មចារីយ៍ (ឧទាហរណ៍ ដោយសារមានមិត្តប្រុស ឬត្រូវគេរំលោភ)។

[៣៩] មើលការវាស់វែង...Steinfath, UNDP ២០០៣

*ឯកសារណាមួយ ដែលបង្ហាញពីកុមារដែលធ្វើការដើម្បីដោះបំណុលក្នុងចំណោមពេស្យាចារកុមារខ្មែរ-វាអាចមាន ប៉ុន្តែវាទំនងជាគ្មាន។ មានតែក្មេងស្រីពីរនាក់ប៉ុណ្ណោះក្នុងចំណោមកុមារ ដែលមានអតីតភាពជាពេស្យាចារ ១៧ នាក់ ដែលយើងបានសម្ភាស ដែលបានដឹងជាមុនថាពួកគេក្លាយជាអ្នកបម្រើផ្លូវភេទ[៤០] ។ ភាគច្រើនត្រូវគេបង្ខំផ្លូវកាយ ហើយពួកគេមិននិយាយស្តីអ្វីបានឡើយពីអ្វីដែលកើតឡើងលើរូបគេ។ ភាគច្រើនក្នុងចំណោមអ្នកទាំងនោះជាកុមារដែលត្រូវជួយសង្គ្រោះមកពីផ្ទះបនពេស្យា ហើយជ្រើសរើសនៅក្នុងមណ្ឌល ហើយរៀនពីមធ្យោបាយផ្សេងៗដើម្បីរកស៊ីចិញ្ចឹមជីវិត ខណៈដែលក្មេងស្រីដទៃទៀតជាញឹកញាប់រត់គេចខ្លួន ហើយវិលត្រឡប់ទៅផ្ទះបនវិញ។*

ផលប៉ះពាល់នៃការជួយសង្គ្រោះគឺខុសគ្នាសំរាប់ក្រុមទាំងពីរនេះ ដោយសារកុមារដែលត្រូវគេបង្ខំអាចជួបនូវបញ្ហាបន្ទាប់ពីជួយសង្គ្រោះពួកគេដែលប៉ះពាល់គេដោយផ្ទាល់។ ឧទាហរណ៍ ការរៀបរាប់ខ្លីៗក្នុងការសិក្សារបស់អង្គការ UNDP (Steinfath ឆ្នាំ ២០០៣) ស្រាយបំភ្លឺថា ប្រសិនបើក្មេងស្រីដែលត្រូវជួយសង្គ្រោះនោះមិនធ្វើការដោះបំណុលគ្រួសារទេ នោះវាអាចធ្លាក់ទៅអោយប្អូនស្រីត្រូវគេបញ្ជូនជំនួសទៅផ្ទះបន។ ការជួយសង្គ្រោះកុមារដែលត្រូវគេចាប់ពង្រត់ ឬបោកប្រាស់យកទៅលក់ពុំសូវមានផលប៉ះពាល់បែបហ្នឹងប៉ុន្មានទេ។

ប៉ុន្តែផលប៉ះពាល់ជាទូទៅនៃការជួយសង្គ្រោះកុមារពីការកេងប្រវ័ញ្ចផ្លូវភេទគឺ មានតំរូវការយ៉ាងខ្លាំងទៅទីជម្រក។ អង្គការ ដែលមានការរៀបចំទុកជាមុនសំរាប់ការជួយសង្គ្រោះដោយមិនបានចាត់វិធានការអោយបានគ្រប់គ្រាន់ដើម្បីផ្តល់ជាជម្រក និងថែទាំកុមារជាក្រោយនោះ គឺមិនបានធ្វើអ្វីដើម្បីទទួលខុសត្រូវទេ[៤១] ។ ការជួយជនរងគ្រោះមិនមែនគ្រាន់តែជួយសង្គ្រោះប៉ុណ្ណោះគ្រប់គ្រាន់ទេ! ផលប៉ះពាល់មួយផ្សេងទៀតនៃប្រតិបត្តិការជួយសង្គ្រោះគឺថា ក្មេងស្រីជាច្រើននឹងចូលក្នុងអាជីវកម្មផ្លូវភេទ។ ផ្ទះបនជាធម្មតានឹងរកកុមារមកដាក់ជំនួសកុមារដែលបានជួយសង្គ្រោះ[៤២] ។ តើនេះមានន័យថា យើងមិនគួរជួយសង្គ្រោះកុមារដែលចង់ចាកចេញពីស្ថានភាពកេងប្រវ័ញ្ចនេះទេឬ? តាមពិតមិនមែនទេ! យ៉ាងណាក៏ដោយវាន័យថា យើងត្រូវតែធ្វើការអត្ថាធិប្បាយនូវអ្វីដែលនឹងកើតឡើង ប្រសិនបើយើងរៀបចំសំរាប់ការវាយឆ្មក់លើផ្ទះបន។ អង្គការដែលបានជួយសង្គ្រោះកុមារតាមរយៈការវាយឆ្មក់ ឬក្នុងករណីមួយចំនួនតាមរយៈការបង់ប្រាក់លោះទៅអោយផ្ទះបន ឬមេបនត្រូវតែដឹងនូវអ្វីជាផលវិបាកដោយសារសកម្មភាពរបស់គេ។ វាត្រូវការអោយមានការយល់ដឹងអោយបាន

---

[៤០] លក់ដូចសត្វមាន់ Sandy Hudd, COSECAM ២០០៣

[៤១] យើងមិនបានថ្កោលទោសពីស្ថានភាពដែលថាជនរងគោះ ឬអតិថិជនដែលអាណិតអាសូរលើកុមារដែលសុំជំនួយ។ អ្វីដែលស្ថិតនៅក្នុងទស្សនៈរបស់យើង ដែលមិនសមរម្យត្រូវគេមិនអើពើនឹងចាត់វិធានការណ៍សំរាប់ការជួយសង្គ្រោះដោយគ្មានការរៀបចំជាមុនសំរាប់រកទីជម្រក និងការថែទាំអោយបានសមរម្យ។

[៤២] មើលទាសករផ្លូវភេទនៅអាស៊ី Louise Brown 2000

ទូលំទូលាយដើម្បីដោះស្រាយបញ្ហានេះ និងកាត់បន្ថយកុមារដែលត្រូវគេជួញដូរឱ្យចូលទៅក្នុងឧស្សាហកម្មផ្លូវភេទអោយមានប្រសិទ្ធិភាព។

## សន្និដ្ឋាន

ចំណងជើងតូចនៃអត្ថបទនេះ **បំណងផ្ទុយទៅនឹងភាពពិត** ត្រូវបានគេជ្រើសរើសដោយសារវាពិពណ៌នាពាក្យបីម៉ាត់លើបញ្ហាចំបងក្នុងតំបន់នៃមជ្ឈមណ្ឌលស្តារលទ្ធភាពកុមារ។ លើកលែងតែ ផ្លែប៉ោមដែលស្អុយរលួយដែលមិនអាចចៀសបានការផ្តល់ការ ថែទាំអោយប្រជាជនទាំងអស់គឺជាចេតនាល្អ និងការផ្តល់សេវាសំរាប់ជនរងគ្រោះកុមារពីការរំលោភបំពាន និងកុមារដែលគេមិនអើពើអោយបានល្អដែលពួកគេអាចធ្វើទៅបាន។ បំណងគឺល្អតែលទ្ធផលជាញឹកញាប់គឺជាឆន្ទៈ។ តើយើងគួរនិយាយយ៉ាងដូចម្តេចអំពីរបកគំហើញដែលដែលបង្ហាញពីចំនួនជនរងគ្រោះ ដែលត្រូវបានសង្គ្រោះជាច្រើនបន្ទាប់ពីស្នាក់នៅក្នុងជម្រកមួយរយៈមកវិលត្រឡប់ទៅរក "ការងារ" ដើមរបស់គេវិញនោះ? លើសពីនេះទៀត ប្រហែលជាងពាក់កណ្តាលហើយប្រហែលជា ៧៥% នៃស្ត្រីក្មេងៗដែលបានទទួលនូវការបណ្តុះបណ្តាលវិជ្ជាជីវរួចហើយនោះរកការងារមិនបានធ្វើ ឬបរាជ័យនឹងអាជីវកម្មរបស់ខ្លួន។ តើអ្វីទៅជាផលប្រយោជន៍នៃការជួយសង្គ្រោះមនុស្សក្មេងៗទាំងអស់នោះ? យើងត្រូវតែធ្វើការពិចារណាពីរឿងនេះនៅពេលកសាងកម្មវិធី និងផ្តល់ជំនួយ។ យើងក៏ត្រូវពិចារណាផងដែនូវផលប៉ះពាល់ពីការជួយសង្គ្រោះជនរងគ្រោះទៅលើកុមារដទៃទៀត។ អង្គការមួយចំនួនធ្វើការអត្ថាធិប្បាយអំពីរឿងនេះ ហើយធ្វើការថ្លឹងថ្លែងពីគុណសម្បត្តិសំរាប់ជនរងគ្រោះ ដែលត្រូវជួយសង្គ្រោះប្រឆាំងនឹងផលប៉ះពាល់អវិជ្ជមានទៅលើអ្នកដទៃ។ ប៉ុន្តែអង្គការភាគច្រើនពុំបានដឹងរឿងនេះអោយបានទូលំទូលាយឡើយ។ តែគួឱ្យសោកស្តាយមានភ្នាក់ងារមួយចំនួនត្រូវបានលើកទឹកចិត្ត តាមរយៈវត្តមានផ្ទាល់ខ្លួនជាងលើផលប្រយោជន៍ជនរងគ្រោះ។ម្យ៉ាងមិញទៀត ក្នុងករណីខ្លះជាធម្មតាពួកគេពុំមានលទ្ធភាពដោះស្រាយលើបញ្ហាធំដុំនោះទេ ហើយក៏ពុំបានដឹងពីផលប៉ះពាល់នៃអំពើរបស់ខ្លួនដែរ។ លើសពីនេះទៀត ភ្នាក់ងារមួយចំនួនតូចគៀងគរតាមរបៀបវារៈផ្ទាល់ខ្លួន ឃោសនាគួរចាប់អារម្មណ៍ក្នុងគោលបំណង ទាក់ទាញអ្នកផ្តល់ជំនួយ ឬព្យាយាមបញ្ចុះបញ្ចូលអោយផ្លាស់ប្តូរសាសនាឬវប្បធម៌ជាដើម។

នៅក្នុងក្របខណ្ឌរបស់ COSECAM សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដោះស្រាយបញ្ហាការរំលោភបំពានលើកុមារ និងសមាជិកអង្គការទាំងអស់កំពុងធ្វើការរួមគ្នាដើម្បីយកឈ្នះលើឧបសគ្គទាំងនេះ ហើយធ្វើអោយបំនងក្លាយជាការពិត។ អត្ថបទនេះគឺជាការប្រឹងប្រែង ដើម្បីឈានមួយជំហានតូចឆ្ពោះទៅរកទិសដៅខាមុខ។

**ភ្នំពេញ**

**មករា ២០០៤**